Peace Corps

# ភ្នាក់ងារ ពីសខ័រ សហរដ្ឋអាមេរិក នៅកម្ពុជា







# របាយការណ៍ប្រចាំឆ្នាំ
# ២០១៨

# មាតិកា


១២ឆ្នាំនៃការកសាងមិត្តភាព និងការផ្តល់សេវាកម្ម ..... i
ទស្សនៈ និងគុណតម្លៃរបស់ភ្នាក់ងារភីសខ័រកម្ពុជា ..... iii
សារលិខិតពីបុគ្គលិកភ្នាក់ងារភីសខ័រកម្ពុជា ..... ១
ទិដ្ឋភាពទូទៅរបស់ភ្នាក់ងារភីសខ័រ ..... ២
ភ្នាក់ងារភីសខ័រប្រចាំនៅកម្ពុជា ..... ៣
ការគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា ..... ៤
អ្នកស្ម័គ្រចិត្តរបស់យើងបច្ចុប្បន្ន ..... ៥
ការបណ្តុះបណ្តាលគ្រូបង្រៀន និងការបង្រៀនភាសាអង់គ្លេស ..... ៦
សមិទ្ធផលសម្រេចបានក្នុងឆ្នាំ២០១៨ ..... ៧
ដំណើររឿងជោគជ័យលើផ្នែកអប់រំភាសាអង់គ្លេស ..... ៨
សកម្មភាពប្រចាំថ្ងៃរបស់អ្នកស្ម័គ្រចិត្តភីសខ័រ ..... ១០
ការអប់រំសុខភាពសហគមន៍ ..... ១២
សមិទ្ធផលសម្រេចបានក្នុងឆ្នាំ២០១៨ ..... ១៣
ដំណើររឿងជោគជ័យលើផ្នែកអប់រំសុខភាព ..... ១៤
គម្រោងអភិវឌ្ឍន៍ដឹកនាំដោយសហគមន៍ ..... ១៦
ដំណើររឿងជោគជ័យលើផ្នែកគម្រោងអភិវឌ្ឍន៍ដឹកនាំដោយសហគមន៍ ..... ១៨
បទពិសោធន៍នៃការរស់នៅជាមួយគ្រួសារខ្មែរ ..... ២០
បទពិសោធន៍នៃការធ្វើការជាមួយដៃគូការងារ ..... ២១

# ១២ឆ្នាំ
# នៃការកសាងមិត្តភាព និងការផ្តល់សេវាកម្ម

## ៦១២

ចំនួនអ្នកស្ម័គ្រចិត្តដែលបានបម្រើការងារ
ស្ម័គ្រចិត្តនៅក្នុងខេត្តចំនួន ១៩ នៃរាជធានីខេត្តទាំង ២៥

## ២០១៨



**ពិធីសច្ចាប្រណិធានរបស់អ្នកស្ម័គ្រចិត្តពីសខ័រ ក្រុមទី១២**

អ្នកស្ម័គ្រចិត្តភីសខ័រចំនួន២៥នាក់ផ្នែក
អប់រំភាសាអង់គ្លេសស្បថចូល
បម្រើការងារនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨
និងត្រូវបម្រើការងារនៅខេត្តមួយចំនួនដូចជា៖

- បាត់ដំបង
- កំពង់ចាម
- កំពង់ឆ្នាំង
- កំពង់ធំ
- ក្រចេះ
- ពោធិ៍សាត់
- ស្ទឹងត្រែង
- ត្បូងឃ្មុំ

## ២០១៧



**ពិធីសច្ចាប្រណិធានរបស់អ្នកស្ម័គ្រចិត្តពីសខ័រ ក្រុមទី១១**

អ្នកស្ម័គ្រចិត្តភីសខ័រចំនួន៧១នាក់ ៣៤នាក់ផ្នែក
អប់រំភាសាអង់គ្លេស និង ៣៧នាក់ផ្នែកអប់រំសុខភាព
ស្បថចូលបម្រើការងារនៅថ្ងៃទី១៥ ខែកញ្ញាឆ្នាំ២០១៧
និងត្រូវបម្រើការងារនៅខេត្តមួយចំនួនដូចជា៖

- បាត់ដំបង
- កំពង់ចាម
- កំពង់ឆ្នាំង
- កំពង់ធំ
- កំពត
- ក្រចេះ
- ព្រៃវែង
- ពោធិ៍សាត់
- សៀមរាប
- ស្វាយរៀង
- តាកែវ
- ត្បូងឃ្មុំ

## ២០១៦



**ពិធីសច្ចាប្រណិធានរបស់អ្នកស្ម័គ្រចិត្តពីសខ័រ ក្រុមទី១០**

អ្នកស្ម័គ្រចិត្តភីសខ័រចំនួន៦៩នាក់ ៣៤នាក់ផ្នែក
អប់រំភាសាអង់គ្លេស និង ៣៥នាក់ផ្នែកអប់រំសុខភាព
ស្បថចូលបម្រើការងារនៅថ្ងៃទី១៦ ខែកញ្ញាឆ្នាំ២០១៦
និងត្រូវបម្រើការងារនៅខេត្តមួយចំនួនដូចជា៖

- បន្ទាយមានជ័យ
- បាត់ដំបង
- កំពង់ចាម
- កំពង់ឆ្នាំង
- កំពង់ស្ពឺ
- កំពង់ធំ
- កំពត
- កោះកុង
- ព្រៃវែង
- ពោធិ៍សាត់
- សៀមរាប
- ស្វាយរៀង
- តាកែវ
- ត្បូងឃ្មុំ

## ២០១៥



**ពិធីសច្ចាប្រណិធានរបស់អ្នកស្ម័គ្រចិត្តពីសខ័រ ក្រុមទី៩**

អ្នកស្ម័គ្រចិត្តភីសខ័រ ចំនួន៦៣នាក់ ៣៤នាក់ផ្នែក
អប់រំភាសាអង់គ្លេស និង ២៩នាក់ផ្នែកអប់រំសុខភាព
ស្បថចូលបំរើការងារនៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៥
និងត្រូវបម្រើការងារនៅខេត្តមួយចំនួនដូចជា៖

- បន្ទាយមានជ័យ
- បាត់ដំបង
- កំពង់ចាម
- កំពង់ឆ្នាំង
- កំពង់ស្ពឺ
- កំពង់ធំ
- កំពត
- កោះកុង
- ព្រៃវែង
- ពោធិ៍សាត់
- សៀមរាប
- ស្វាយរៀង
- តាកែវ
- ត្បូងឃ្មុំ

## ២០១៤



**ពិធីសច្ចាប្រណិធានរបស់អ្នកស្ម័គ្រចិត្តពីសខ័រ ក្រុមទី៨**

អ្នកស្ម័គ្រចិត្តភីសខ័រ ចំនួន៥៣នាក់ ២៩នាក់ផ្នែក
អប់រំភាសាអង់គ្លេស និង ២៤នាក់ផ្នែកអប់រំសុខភាព
ស្បថចូលបំរើការងារនៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤
និងត្រូវបម្រើការងារនៅខេត្តមួយចំនួនដូចជា៖

- បន្ទាយមានជ័យ
- បាត់ដំបង
- កំពង់ចាម
- កំពង់ស្ពឺ
- កំពង់ធំ
- កំពត
- កោះកុង
- ព្រៃវែង
- ពោធិ៍សាត់
- សៀមរាប

## ២០១៣



**ពិធីសច្ចាប្រណិធានរបស់អ្នកស្ម័គ្រចិត្តពីសខ័រ ក្រុមទី៧**

អ្នកស្ម័គ្រចិត្តភីសខ័រ ចំនួន៤៦នាក់ ២៩នាក់ផ្នែក
អប់រំភាសាអង់គ្លេស និង ១៧នាក់ផ្នែកអប់រំសុខភាព
ស្បថចូលបំរើការងារនៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៣
និងត្រូវបម្រើការងារនៅខេត្តមួយចំនួនដូចជា៖

- បាត់ដំបង
- កំពង់ចាម
- កំពង់ឆ្នាំង
- កំពង់ស្ពឺ
- កំពង់ធំ
- កំពត
- កណ្តាល
- កោះកុង
- ភ្នំពេញ
- ព្រៃវែង
- ពោធិ៍សាត់
- សៀមរាប
- ស្វាយរៀង
- តាកែវ
- ត្បូងឃ្មុំ

## ២០១២



**ពិធីសច្ចាប្រណិធានរបស់អ្នកស្ម័គ្រចិត្តពីសខ័រ ក្រុមទី៦**

អ្នកស្ម័គ្រចិត្តភីសខ័រ ចំនួន៥៨នាក់ ២៩នាក់ផ្នែក
អប់រំភាសាអង់គ្លេស និង ២៩នាក់ផ្នែកអប់រំសុខភាព
ស្បថចូលបំរើការងារនៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១២
និងត្រូវបម្រើការងារនៅខេត្តមួយចំនួនដូចជា៖

- បន្ទាយមានជ័យ
- បាត់ដំបង
- កំពង់ចាម
- កំពង់ឆ្នាំង
- កំពង់ស្ពឺ
- កំពង់ធំ
- កំពត
- កោះកុង
- ព្រះសីហនុ
- ព្រៃវែង
- ពោធិ៍សាត់
- សៀមរាប
- ស្វាយរៀង
- តាកែវ

## ២០១១



**ពិធីសច្ចាប្រណិធានរបស់អ្នកស្ម័គ្រចិត្តពីសខ័រ ក្រុមទី៥**

អ្នកស្ម័គ្រចិត្តភីសខ័រ ចំនួន៥៩នាក់ ៤០នាក់ផ្នែក
អប់រំភាសាអង់គ្លេស និង ១៩នាក់ផ្នែកអប់រំសុខភាព
ស្បថចូលបំរើការងារនៅថ្ងៃទី៣ ខែតុលា ឆ្នាំ២០១១
និងត្រូវបម្រើការងារនៅខេត្តមួយចំនួនដូចជា៖

- បន្ទាយមានជ័យ
- បាត់ដំបង
- កំពង់ចាម
- កំពង់ឆ្នាំង
- កំពង់ស្ពឺ
- កំពង់ធំ
- កំពត
- កណ្តាល
- កោះកុង
- ភ្នំពេញ
- ព្រះសីហនុ
- ពោធិ៍សាត់
- សៀមរាប
- ស្វាយរៀង
- តាកែវ

## ២០១០



**ពិធីសច្ចាប្រណិធានរបស់អ្នកស្ម័គ្រចិត្តពីសខ័រ ក្រុមទី៤ និង អ្នកស្ម័គ្រចិត្តផ្នែកអប់រំសុខភាពសហគមន៍ក្រុមដំបូង**

អ្នកស្ម័គ្រចិត្តភីសខ័រ ចំនួន៤៩នាក់ ៣១នាក់ផ្នែកអប់រំភាសាអង់គ្លេស និង
១៨នាក់ផ្នែកអប់រំសុខភាព ស្បថចូលបំរើការងារនៅថ្ងៃទី២៣ ខែកញ្ញា
ឆ្នាំ២០១០ និងត្រូវបម្រើការងារនៅខេត្តមួយចំនួនដូចជា៖

- បន្ទាយមានជ័យ
- បាត់ដំបង
- កំពង់ចាម
- កំពង់ឆ្នាំង
- កំពង់ស្ពឺ
- កំពង់ធំ
- កំពត
- កោះកុង
- ភ្នំពេញ
- ព្រះសីហនុ
- ពោធិ៍សាត់
- សៀមរាប
- ស្វាយរៀង
- តាកែវ

**អនុស្សរណៈយោគយល់ជាមួយ ក្រសួងសុខាភិបាល**

Peace Corps

ថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០១០
ដើម្បីចាប់ផ្តើមកម្មវិធី
ការអប់រំសុខភាពសហគមន៍។

## ២០០៩



**ពិធីសច្ចាប្រណិធានរបស់អ្នកស្ម័គ្រចិត្តពីសខ័រ ក្រុមទី៣**

អ្នកស្ម័គ្រចិត្តផ្នែកអប់រំភាសាអង់គ្លេស ចំនួន
៤២នាក់ ស្បថចូលបំរើការងារនៅថ្ងៃទី២០
ខែកញ្ញា ឆ្នាំ២០០៩ និងត្រូវបម្រើការងារនៅ
ខេត្តមួយចំនួនដូចជា៖

- បន្ទាយមានជ័យ
- បាត់ដំបង
- កំពង់ចាម
- កំពង់ឆ្នាំង
- កំពង់ធំ
- កំពត
- ភ្នំពេញ
- ព្រៃវែង
- ពោធិ៍សាត់
- សៀមរាប
- ស្វាយរៀង
- តាកែវ

## ២០០៨



**ពិធីសច្ចាប្រណិធានរបស់អ្នកស្ម័គ្រចិត្តពីសខ័រ ក្រុមទី២**

អ្នកស្ម័គ្រចិត្តផ្នែកអប់រំភាសាអង់គ្លេស ចំនួន
៣៤នាក់ ស្បថចូលបំរើការងារនៅថ្ងៃទី៤
ខែតុលា ឆ្នាំ២០០៨ និងត្រូវបម្រើការងារនៅ
ខេត្តមួយចំនួនដូចជា៖

- បន្ទាយមានជ័យ
- បាត់ដំបង
- កំពង់ចាម
- កំពង់ឆ្នាំង
- កំពង់ធំ
- កំពត
- កណ្តាល
- ព្រៃវែង
- ពោធិ៍សាត់
- សៀមរាប
- ស្វាយរៀង
- តាកែវ

## ២០០៧



**ពិធីសច្ចាប្រណិធានរបស់អ្នកស្ម័គ្រចិត្តពីសខ័រ ក្រុមទី១**

អ្នកស្ម័គ្រចិត្តផ្នែកអប់រំភាសាអង់គ្លេសក្រុមទី១
ចំនួន២៩នាក់ ស្បថចូលបំរើការងារនៅថ្ងៃទី២
ខែមេសា ឆ្នាំ២០០៧ និងត្រូវបម្រើ
ការងារនៅខេត្តមួយចំនួនដូចជា៖

- បាត់ដំបង
- កំពង់ចាម
- កំពត
- ព្រៃវែង
- សៀមរាប
- ស្វាយរៀង
- តាកែវ



**អ្នកស្ម័គ្រចិត្តពីសខ័រចូលគាល់ព្រះមហាក្សត្រ**

អ្នកស្ម័គ្រចិត្តភីសខ័រ និងនាយកប្រចាំប្រទេស
របស់ភ្នាក់ងារ ភីសខ័រប្រចាំកម្ពុជាចូលគាល់
ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ
**នរោត្តម សីហមុនី**

## ២០០៦

**បើកការិយាល័យ**

ភ្នាក់ងារភីសខ័រ បើកការិយាល័យ
ជាផ្លូវការដំបូងនៅក្នុងប្រទេស
កម្ពុជា។

Peace Corps

**ចុះហត្ថលេខាលើអនុស្សរណៈយោគយល់ជាមួយ ក្រសួងអប់រំ យុវជន និងកីឡា**

ភ្នាក់ងារភីសខ័រ ចុះហត្ថលេខាលើអនុស្សរណៈយោគយល់ជាមួយ
ក្រសួងអប់រំ យុវជន និងកីឡានៅថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០០៦ ដើម្បី
ចាប់ផ្តើមកម្មវិធី ការបណ្តុះបណ្តាលគ្រូបង្រៀន និងការបង្រៀនភាសា
អង់គ្លេស។




# ទស្សនៈ និង គុណតម្លៃ របស់ភ្នាក់ងារភីសខ័រកម្ពុជា

# សារលិខិតពីបុគ្គលិកភ្នាក់ងារភីសខ័រកម្ពុជា



បុគ្គលិកភ្នាក់ងារភីសខ័រកម្ពុជា

បេសកកម្មរបស់ភ្នាក់ងារភីសខ័រ គឺ "សន្តិភាពពិភពលោក និងមិត្តភាព"។ យើងសម្រេចបាននូវបេសកកម្មរបស់យើង តាមរយៈការបម្រើសេវាកម្ម។ អ្នកស្ម័គ្រចិត្តរបស់យើង រស់នៅនិងធ្វើការរយៈពេល ២ ឆ្នាំ នៅក្នុងសហគមន៍ជាមួយក្រុមគ្រួសារម្ចាស់ផ្ទះដើម្បីបានជួបផ្ទាល់និងសម្រុះខ្លួនជាមួយប្រពៃណីវប្បធម៌ក្នុងមូលដ្ឋាន។ ការនេះជួយពួកគេឲ្យអាចចូលរួមចំណែកបានល្អប្រសើរទៅក្នុងការអភិវឌ្ឍប្រទេសកម្ពុជា និងប្រើប្រាស់ជំនាញបច្ចេកទេសរបស់ពួកគេឲ្យបានសមស្របនៅក្នុងមជ្ឈដ្ឋាន និងវប្បធម៌ថ្មីៗ។

កាលពីអំឡុងឆ្នាំមុន អ្នកស្ម័គ្រចិត្តរបស់យើងដែលទទួលបានការតម្រង់ទិសសេវាកម្មការងារ បានធ្វើការងារនៅក្នុងបំណែងចែកភារកិច្ចដ៏សំខាន់ជាមួយគ្រូបង្រៀន និងភាគីដៃគូជំនាញផ្នែកសេវាសុខាភិបាល ដើម្បីចូលរួមចំណែកដល់ការអភិវឌ្ឍភាសាអង់គ្លេស និងការអប់រំសុខភាពនៅក្នុងប្រទេសកម្ពុជា។ បន្ថែមលើនេះ ពួកគេបានធ្វើការជួយសហការីនិងមិត្តភក្តិនៅតាមមូលដ្ឋាននៅក្នុងគម្រោងអភិវឌ្ឍសហគមន៍ជាច្រើន ដូចជា ការអភិវឌ្ឍសួនបន្លែនៅតាមសាលារៀន ដែលនឹងជួយលើកកម្ពស់អាហារូបត្ថម្ភដល់កុមារ និងក្រុមគ្រួសារនានា ឬបង្កើតបណ្ណាល័យមួយដែលជាធនធានសម្រាប់សាលារៀន ឬសហគមន៍។

មិនថាធ្វើការងារក្នុងបំណែងចែកការងារសំខាន់របស់ពួកគេ ឬធ្វើការជាមួយសហគមន៍នៅក្នុងគម្រោងអភិវឌ្ឍណាមួយនោះទេ គោលដៅសំខាន់នោះគឺ ការកសាងសមត្ថភាពមូលដ្ឋាន។ តាមរយៈការធ្វើការងារជាមួយអ្នកស្ម័គ្រចិត្ត សមាជិកសហគមន៍អាចរៀនសូត្រដើម្បីកំណត់ពីសមត្ថភាពភាពជាអ្នកដឹកនាំរបស់ពួកគេផ្ទាល់ រៀនសូត្រអំពីរបៀបទទួលបានធនធាននានា និងអនុវត្តការងាររួមគ្នាឆ្ពោះទៅរកគោលដៅអភិវឌ្ឍសហគមន៍ដែលបំពេញតាមតម្រូវការ និងឱកាសនានាដែលពួកគេបានកំណត់ទុក។ តួនាទីរបស់អ្នកស្ម័គ្រចិត្ត គឺដើម្បីចូលរួមក្នុងនាមជាសមាជិកថ្មីរបស់សហគមន៍ និងជួយសម្របសម្រួលដល់ដំណើរការនេះ។

នៅពេលកំពុងបំពេញការងារនិងរស់នៅក្នុងសហគមន៍ អ្នកស្ម័គ្រចិត្តរបស់យើង ក៏បានចែករំលែកនូវវប្បធម៌និងប្រពៃណីដ៏សម្បូរបែបរបស់សហរដ្ឋអាមេរិក ដើម្បីឲ្យប្រជាជនកម្ពុជាអាចយល់ដឹងបានច្បាស់អំពីប្រទេសរបស់យើងតាមរយៈការកសាងសម្ព័ន្ធមេត្រីភាពជាច្រើន។ នៅពេលធ្វើបែបនេះ អ្នកស្ម័គ្រចិត្តរបស់យើងអាចចែករំលែកអ្វីដែលពួកគេបានរៀនអំពីប្រពៃ និងវប្បធម៌ដ៏សម្បូរបែបរបស់កម្ពុជាទៅដល់ក្រុមគ្រួសារនិងមិត្តភក្តិនៅសហរដ្ឋអាមេរិក។ មិត្តភាពដែលបានបង្កើតឡើងក្នុងអំឡុងពេលពីរឆ្នាំនៃការរស់នៅនិងធ្វើការនៅក្នុងសហគមន៍ក្នុងប្រទេសកម្ពុជា តាមរយៈការចែករំលែកព័ត៌មានឲ្យគ្នាទៅវិញទៅមកអាចស្ថិតនៅជាប់ជាដរាបពេញមួយជីវិត និងជាកម្លាំងជំរុញនៃបេសកកម្មរបស់យើង ដើម្បីកសាងសន្តិភាពពិភពលោក និងមិត្តភាព។

យើងបន្ថ្លែងអំណរគុណដល់ភាគីម្ចាស់ផ្ទះរាជរដ្ឋាភិបាលកម្ពុជា ដែលបានធ្វើឲ្យការងារនេះអាចសម្រេចទៅបាន តាមរយៈការអញ្ជើញភ្នាក់ងារភីសខ័រ មកធ្វើការក្នុងភាពជាដៃគូ ដើម្បីសម្រេចបាននូវចំណុចអាទិភាពនៃការអភិវឌ្ឍរបស់ពួកគេនៅកម្រិតថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់ឃុំ។ ឆ្នាំនេះជាខួបគម្រប់ ១២ ឆ្នាំ ដែលយើងបានធ្វើការជាមួយមន្ត្រីកម្ពុជា សមភាគី អ្នកជំនាញនៅក្នុងស្ថាប័នសុខាភិបាលនិងអប់រំ និងការកសាងទំនាក់ទំនងជាមួយក្រុមគ្រួសារ សហគមន៍ និងបុគ្គលជាច្រើន។ ទិន្នន័យនិងសាច់រឿងដែលបានចែករំលែកនៅទីនេះ តំណាងឲ្យស្មារតីនៃយុទ្ធសាស្ត្រអភិវឌ្ឍរវាងមនុស្ស និងមនុស្សរបស់ភ្នាក់ងារភីសខ័រ ដែលការងារនេះ អាចអនុវត្តទៅបាន លុះត្រាតែយើងរួមគ្នាសិក្សារៀនសូត្រ និងរីកលូតលាស់ទាំងអស់គ្នា។ យើងពិតជាមានមោទនភាពក្នុងការចែករំលែកនូវសមិទ្ធផលនៃកិច្ចសហប្រតិបត្តិការរបស់អ្នកស្ម័គ្រចិត្តរបស់យើង និងសមភាគីកម្ពុជានៅក្នុងឆ្នាំ២០១៨ នៅក្នុងរបាយការណ៍ប្រចាំឆ្នាំនេះ។

# ទិដ្ឋភាពទូទៅរបស់ភ្នាក់ងារភីសខ័រ

ភ្នាក់ងារ ភីសខ័រ បញ្ជូនជនជាតិអាមេរិកល្អៗប្រកបដោយចំណេះដឹង ដែលជាតំណាងអោយសហរដ្ឋអាមេរិក ទៅក្រៅប្រទេស ដើម្បីជួយដោះស្រាយបញ្ហាដែលជាតម្រូវការបន្ទាន់របស់ប្រជាជនទូទាំងពិភពលោក ។ អ្នកស្ម័គ្រចិត្តទាំងអស់ ធ្វើការនៅតាមសហគមន៍ដើម្បីបង្កើតដំណោះស្រាយប្រកបដោយនិរន្តរភាព ដែលឆ្លើយតបនឹងបញ្ហាផ្សេងៗក្នុងវិស័យកសិកម្ម ការអភិវឌ្ឍសេដ្ឋកិច្ចសហគមន៍ ការអប់រំ បរិស្ថាន សុខភាព និងការអភិវឌ្ឍយុវជន ។ តាមរយៈការបម្រើសេវាកម្មរបស់ពួកគេ អ្នកស្ម័គ្រចិត្តទាំងអស់ទទួលបាននូវការយល់ដឹងអំពីវប្បធម៌ ពិសេសជាមួយនឹងការប្តេជ្ញាចិត្តក្នុងមួយជីវិតរបស់គេក្នុងការបម្រើការងារដែលអាចអោយគេស្ថិតក្នុងតួនាទីមួយដែលនាំអោយពួកគេទទួលបានភាពជោគជ័យក្នុងសង្គមបច្ចុប្បន្ននេះ ។

ភ្នាក់ងារនេះបានចាប់ផ្តើមតាំងពីឆ្នាំ១៩៦០មកម្លេះ នៅពេលដែលអតីតសមាជិកព្រឹទ្ធសភាលោក John F. Kennedy បាននាំនិស្សិតនៅសកលវិទ្យាល័យ Michigan អោយបម្រើប្រទេសរបស់ពួកគេ ដោយការរស់នៅ និងធ្វើការនៅក្នុងតំបន់ដាច់ស្រយាលមួយចំនួននៃពិភពលោក ។ លោកបានបណ្តុះអោយមានចលនាក្នុងចំណោមយុវជនអាមេរិកដែលបានជំរុញប្រទេសជាតិទាំងមូល និងបានដឹកនាំរហូតដល់មានការបង្កើតឡើងនូវភ្នាក់ងារ ភីសខ័រ ។ នៅក្នុងពិភពលោកមួយដែលពោរពេញទៅដោយការផ្លាស់ប្តូរ ភ្នាក់ងារនេះ បានក្លាយជាភ្នាក់ងារឆ្នើមដែលប្រកបដោយភាពស្វាហាប់ និងដំណើរឆ្ពោះទៅមុខក្នុងវិស័យសេវាកម្ម អន្តរជាតិ ដោយសារគំនិតច្នៃប្រឌិតថ្មី និងសេចក្តីអាណិតមេត្តារបស់ខ្លួន ។ ទោះបីជាយ៉ាងណាក៏ដោយ បេសកកម្មដំបូងរបស់ភ្នាក់ងារនេះគឺនៅតែមិនផ្លាស់ប្តូរ៖

## បេសកកម្មរបស់ភ្នាក់ងារ ភីសខ័រ

ដើម្បីបង្កើនមិត្តភាព និងសន្តិភាពនៅលើពិភពលោក ដោយបំពេញនូវគោលដៅចំនួនបី៖

១ *ផ្តល់អ្នកស្ម័គ្រចិត្តទាំងបុរស និងស្ត្រី ដែលបានទទួលការបណ្តុះបណ្តាល ទៅចូលរួមជួយប្រជាជននៅក្នុងបណ្តាប្រទេសដែលចាប់អារម្មណ៍លើភ្នាក់ងារ ភីសខ័រ ។*

២ *ជួយអ្នកស្ម័គ្រចិត្តអាមេរិកអោយមានការយល់ដឹងកាន់តែប្រសើរអំពីប្រជាជនទាំងឡាយដែលពួកគេធ្វើការជាមួយ ។*

៣ *ជួយបង្កើនការយល់ដឹងរបស់ប្រជាជននៅជុំវិញពិភពលោកអោយបានយល់ដឹងកាន់តែប្រសើរអំពីជនជាតិអាមេរិក។*



*លោកប្រធានាធិបតី John F. Kennedy និងនាយកភ្នាក់ងារ ភីសខ័រ លោក Sargent Shriver ស្វាគមន៍អ្នកស្ម័គ្រចិត្តភ្នាក់ងារ ភីសខ័រ ទៅកាន់ប្រទេស Tanganyika និង Ghana នៅក្នុងការិយាល័យរបស់លោកប្រធានាធិបតី ។*



*លោកប្រធានាធិបតី John F. Kennedy ស្វាគមន៍អ្នកស្ម័គ្រចិត្តនៅថ្ងៃទី ២៨ ខែសីហា ឆ្នាំ១៩៦១ ។*

### ប្រវត្តិ

| | |
|---|---|
| ត្រូវបានបង្កើតជាផ្លូវការ | ថ្ងៃទី ០១ ខែមីនា ឆ្នាំ១៩៦១ |
| ជនជាតិអាមេរិកដែលបានបម្រើការងារ | ច្រើនជាង ២៣០,០០០ |
| ប្រទេសសាមីដែលត្រូវបានបម្រើមកដល់បច្ចុប្បន្ន | ១៤១ |

### ភ្នាក់ងារភីសខ័រ បច្ចុប្បន្ន៖

| | |
|---|---|
| នាយិកាភ្នាក់ងារភីសខ័រ | ចូឌី អលស៊ិន<br>អតីតអ្នកស្ម័គ្រចិត្តភីសខ័រ នៅប្រទេសទុយនេស៊ី ឆ្នាំ១៩៦៦-១៩៦៨ |
| ប្រទេសម្ចាស់ផ្ទះ | ៦៤ |
| អ្នកស្ម័គ្រចិត្ត និងសិក្ខាកាម | ៧,៣៧៦ |
| យេនឌ័រ | ស្ត្រី ៦៣% និង បុរស ៣៧% |
| ស្ថានភាពគ្រួសារ | នៅលីវ ៩៨% និងរៀបការហើយ ២% |
| ជនជាតិភាគតិច | ៣២% នៃអ្នកស្ម័គ្រចិត្តទាំងអស់ |
| អាយុជាមធ្យម | ២៨ |
| អ្នកស្ម័គ្រដែលមានអាយុលើសពី៥០ឆ្នាំ | ៦% នៃអ្នកស្ម័គ្រចិត្តទាំងអស់ |




*ផែនទីបង្ហាញពីខេត្តទាំងឡាយដែលមានអ្នកស្ម័គ្រចិត្ត ភីសខ័រ បម្រើការងារចាប់តាំងពីកម្មវិធីចាប់ផ្តើមនៅក្នុងឆ្នាំ ២០០៧ មក*

# ភ្នាក់ងារភីសខ័រ ប្រចាំនៅកម្ពុជា

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញភ្នាក់ងារភីសខ័រ អោយបើកដំណើរការកម្មវិធីក្នុងប្រទេសកម្ពុជា នៅចុងឆ្នាំ ១៩៩២ ហើយកិច្ចព្រមព្រៀងរវាងប្រទេសទាំងពីរ ត្រូវបានចុះហត្ថលេខានៅឆ្នាំ ១៩៩៤ ។ ទោះបីជាយ៉ាងណាក៏ដោយស្ថានភាពនយោបាយមិនមានស្ថេរភាពគ្រប់គ្រាន់ សម្រាប់អោយអ្នកស្ម័គ្រចិត្តចូលមកកម្ពុជាក្នុងពេលនោះ ។ នៅឆ្នាំ២០០៤ ការពិភាក្សាគ្នាអំពីការបង្កើតអោយមានភ្នាក់ងារ ភីសខ័រកម្ពុជាបានបន្តទៀត ហើយភ្នាក់ងារ ភីសខ័រ បានស្វាគមន៍អ្នកស្ម័គ្រចិត្តក្រុមទីមួយមកកាន់ប្រទេសកម្ពុជា នៅឆ្នាំ ២០០៧ ។

មនុស្សម្នាក់ៗដែលត្រូវបម្រើការជាអ្នកស្ម័គ្រចិត្តភ្នាក់ងារភីសខ័រ ត្រូវបានជ្រើសរើសតាមរយៈដំណើរការដាក់ពាក្យសុំដែលពោរពេញទៅដោយការប្រកួតប្រជែង ។ អ្នកស្ម័គ្រចិត្តភ្នាក់ងារភីសខ័រ មានអាយុចាប់ពី ២២ ដល់ ៧៥ឆ្នាំ ហើយតំណាងអោយក្រុមជនជាតិ និងសាសន៍ផ្សេងៗគ្នា ។ អ្នកស្ម័គ្រចិត្តភ្នាក់ងារ ភីសខ័រ ភាគច្រើនមានសញ្ញាបត្រ បរិញ្ញាបត្រ ឬ ខ្ពស់ជាងនេះ ។ អ្នកស្ម័គ្រចិត្តមកប្រទេសកម្ពុជាដើម្បីប្រើប្រាស់ជំនាញនិងចំណេះដឹងរបស់ពួកគេ ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍប្រទេស តាមរយៈសកម្មភាពផ្ទាល់នៅតាមសហគមន៍ ។ បន្ទាប់ពីបានមកដល់ប្រទេសកម្ពុជា អ្នកស្ម័គ្រចិត្តភ្នាក់ងារភីសខ័រ ត្រូវឆ្លងកាត់វគ្គបណ្តុះបណ្តាលជាច្រើនលើផ្នែកភាសា វប្បធម៌ សុខភាព សុវត្ថិភាព និងបច្ចេកទេស ។ ក្នុងកំឡុងពេលនៃការបំពេញសេវាកម្មរបស់ពួកគេ ភ្នាក់ងារភីសខ័រនឹងផ្តល់ឱកាសអោយមានវគ្គបណ្តុះបណ្តាលដល់អ្នកស្ម័គ្រចិត្តនិងគ្រូបង្រៀនដៃគូរបស់ពួកគេដើម្បីពង្រឹងជំនាញបច្ចេកទេស និងភាសា ។

អ្នកស្ម័គ្រចិត្តរស់នៅជាមួយគ្រួសារខ្មែរ ដែលមានជីវភាពប្រហាក់ប្រហែលនឹងពលរដ្ឋកម្ពុជានៅក្នុងសហគមន៍របស់ពួកគេ។ ពួកគេធ្វើការងារជាមួយប្រជាជនកម្ពុជា ដើម្បីជួយពួកគេអោយអនុវត្តការងារដែលមានប្រសិទ្ធភាពដើម្បីឈានទៅរកអនាគតមួយដ៏ល្អប្រសើរជាងមុនសម្រាប់សហគមន៍ ក៏ដូចជាប្រទេសកម្ពុជាទាំងមូល ។

## គម្រោងក្នុងពេលបច្ចុប្បន្ន៖

**ការបណ្តុះបណ្តាលគ្រូបង្រៀន និងការបង្រៀនភាសាអង់គ្លេស**

**ការអប់រំសុខភាពសហគមន៍**




*ចំនួនអ្នកស្ម័គ្រចិត្តក្នុងឆ្នាំនិមួយៗចាប់តាំងពីឆ្នាំ២០០៧*




*ភាគរយនៃអ្នកស្ម័គ្រចិត្តក្នុងកម្មវិធីអប់រំភាសាអង់គ្លេស និងអប់រំសុខភាព មកដល់ពេលបច្ចុប្បន្ន*




ពិធីសច្ចាប្រណិធានរបស់អ្នកស្ម័គ្រចិត្តភីសខ័រក្រុមទី ១២

# ការគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា

ភាពជាដៃគូជាមួយរាជរដ្ឋាភិបាលកម្ពុជា គឺជាមូលដ្ឋានគ្រឹះនៃការងារជាច្រើនរបស់ភ្នាក់ងារភីសខ័រ កម្ពុជា។ ភាពជាដៃគូរបស់យើងចាប់ផ្តើមជាមួយក្រសួងអប់រំ យុវជន និងកីឡា ស្ថិតក្រោមអនុស្សារណៈនៃការយោគយល់គ្នាឆ្នាំ២០០៧ ក្នុងការបញ្ជូនអ្នកស្ម័គ្រចិត្តភីសខ័រ ទៅកាន់វិទ្យាល័យនានាដើម្បីផ្តល់ការគាំទ្រនៅក្នុងការបង្រៀនភាសាអង់គ្លេស។ ភាពជាដៃគូរបស់យើងបានពង្រីកបន្ថែមទៀតទៅដល់ក្រសួងសុខាភិបាលនៅក្នុងឆ្នាំ២០១០ តាមរយៈអនុស្សារណៈនៃការយោគយល់គ្នា ដើម្បីបញ្ជូនអ្នកស្ម័គ្រចិត្តភីសខ័រ ទៅកាន់មណ្ឌលសុខភាពនៅតាមទីជនបទ ដែលពួកគេបានផ្តល់ការអប់រំសុខភាពនៅទីនោះ។ ភាពជាដៃគូទាំងនេះ បានធ្វើឲ្យកម្មវិធីនេះអាចដំណើរការទៅបាន ដោយបានផ្សព្វផ្សាយទៅដល់ប្រជាជនកម្ពុជាជាង ១០០,០០០ នាក់។

ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាលបានផ្តល់ការណែនាំលើទិសដៅយុទ្ធសាស្ត្ររបស់ភ្នាក់ងារភីសខ័រ កម្ពុជា និងការពង្រីកសកម្មភាពនៅតាមទីតាំងភូមិសាស្ត្រ។ មន្ត្រីកម្រិតថ្នាក់ខេត្តនិងថ្នាក់ស្រុកនៅក្នុងក្រសួងទាំងពីរនេះ បានជួយដល់ការកំណត់ទីតាំងនានាសម្រាប់ដាក់បញ្ចូលអ្នកស្ម័គ្រចិត្ត។ ប្រធានមណ្ឌលសុខភាព និងនាយកសាលា ជាអ្នកគ្រប់គ្រងលើអ្នកស្ម័គ្រចិត្តភីសខ័រ។ នៅក្នុងឆ្នាំ ២០១៨ ក្រោមចក្ខុវិស័យរបស់ក្រសួងអប់រំ យុវជន និងកីឡា ភ្នាក់ងារភីសខ័រ កម្ពុជា បានពង្រីកនូវការបង្រៀនភាសាអង់គ្លេសរបស់ខ្លួនដោយចាប់ផ្តើមកម្មវិធីសាកល្បងនៅតាមសាលារៀនចំនួន ១៥ កន្លែង ដើម្បីធ្វើការងារជាមួយគ្រូបង្រៀន និងសិស្សានុសិស្សនៅថ្នាក់ទី៤ ទី៥ និងទី៦។ ដោយមានការគាំទ្រ និងការណែនាំជាបន្តបន្ទាប់ពីក្រសួង យើងនឹងអាចធ្វើឲ្យគម្រោងនេះលេចចេញជារូបរាងឡើងបាននៅក្នុងឆ្នាំ២០១៩។

ក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ផ្តល់នូវការអនុញ្ញាតសម្រាប់ភ្នាក់ងារភីសខ័រ ដើម្បីធ្វើការនៅក្នុងប្រទេសកម្ពុជា និងផ្តល់ទិដ្ឋការជូនដល់អ្នកស្ម័គ្រចិត្តរបស់អង្គការ។ ក្រសួងមហាផ្ទៃ នៅកម្រិតថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់ឃុំ បានជួយយើងក្នុងការការពារសុវត្ថិភាពក្រុមស្ម័គ្រចិត្ត និងផ្តល់ការគាំទ្រសង្គ្រោះបន្ទាន់។

ភ្នាក់ងារភីសខ័រកម្ពុជា សូមថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់ការជួយណែនាំ ការសហការការងារ និងការជំរុញលើកទឹកចិត្ត។



*មន្ត្រីមានសមត្ថកិច្ចមានមតិសំណេះសំណាលក្នុងកម្មវិធីបិទវគ្គបណ្តុះបណ្តាលមុនពេលបំពេញការងារជាអ្នកស្ម័គ្រចិត្ត*



*លោកទីប្រឹក្សាជាន់ខ្ពស់ ផាមី ហៀខក់ និង មន្ត្រីមានសមត្ថកិច្ចមានមតិខេត្តតាកែវ ចូលរួមកម្មវិធីបិទវគ្គបណ្តុះបណ្តាល*



អ្នកស្ម័គ្រចិត្តផ្នែកអប់រំភាសាអង់គ្លេសក្រុមទី១១ ចូលរួមវគ្គបណ្តុះបណ្តាល



អ្នកស្ម័គ្រចិត្តផ្នែកអប់រំសុខភាពសហគមន៍ក្រុមទី១១ ចូលរួមវគ្គបណ្តុះបណ្តាល

# អ្នកស្ម័គ្រចិត្តរបស់យើងបច្ចុប្បន្ន

## ស្ថិតិឆ្នាំ ២០១៨

| | | | |
|---|---|---|---|
| ចំនួនអ្នកស្ម័គ្រចិត្ត | ៧៤នាក់៖ បម្រើការងារនៅក្នុង រាជធានីខេត្តចំនួន ១៦ | ចាប់ពីអាយុ ២០ ដល់២៩ឆ្នាំ៖ ៩០%<br>ចាប់ពីអាយុ ៣០ ដល់ ៣៩ឆ្នាំ៖ ៦%<br>ចាប់ពីអាយុ ៤០ ដល់ ៦២ឆ្នាំ៖ ៤% | អាយុ |
| គម្រោង | ៤៧នាក់៖ ការបណ្តុះបណ្តាលគ្រូបង្រៀន និងការបង្រៀនភាសាអង់គ្លេស<br>២៧នាក់៖ ការអប់រំសុខភាពសហគមន៍ | អ្នកស្ម័គ្រចិត្តរបស់យើងបច្ចុប្បន្នមកពីរដ្ឋ ចំនួន ៣៨ នៃរដ្ឋទាំង៥០ របស់ សហរដ្ឋអាមេរិក | រដ្ឋនៃសហរដ្ឋអាមេរិក |
| យេនឌ័រ | ៤១នាក់៖ ស្ត្រី<br>៣៣នាក់៖ បុរស | | |

### ការបណ្តុះបណ្តាលមុនពេលបំពេញការងារស្ម័គ្រចិត្ត

| | | |
|---|---|---|
| សិក្សាភាសាខ្មែរ | : | ១២៥ម៉ោង សម្រាប់អ្នកស្ម័គ្រចិត្តផ្នែកអប់រំភាសាអង់គ្លេស |
| សិក្សផ្នែកបច្ចេកទេសការងារ ជាមួយដៃគូជនជាតិខ្មែរ | : | ៥១ម៉ោង សម្រាប់អ្នកស្ម័គ្រចិត្តផ្នែកអប់រំភាសាអង់គ្លេស |
| សិក្សាវប្បធម៌ខ្មែរ | : | ៣២ម៉ោង |
| អនុវត្តការងារ | : | ៦៥ម៉ោង សម្រាប់អ្នកស្ម័គ្រចិត្តផ្នែកអប់រំភាសាអង់គ្លេស |
| ការរស់នៅប្រចាំថ្ងៃ | : | រស់នៅជាមួយគ្រួសារខ្មែរ |




អ្នកស្ម័គ្រចិត្តផ្នែកអប់រំសុខភាពសហគមន៍ក្រុមទី១១ ចូលរួមវគ្គបណ្តុះបណ្តាល











# ការបណ្តុះបណ្តាលគ្រូបង្រៀន និងការបង្រៀនភាសាអង់គ្លេស

គម្រោងបណ្តុះបណ្តាលគ្រូបង្រៀន និងការបង្រៀនភាសាអង់គ្លេស បាននឹងកំពុងធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រសួងអប់រំ យុវជន និងកីឡា នៃប្រទេសកម្ពុជាតាំងពីឆ្នាំ២០០៧។ គម្រោងនេះបានធ្វើការដើម្បីអភិវឌ្ឍជំនាញគិតដោយវិភាគ និងភាសាអង់គ្លេសដល់សិស្សានុសិស្ស គ្រូបង្រៀន និងប្រជាជនក្នុងសហគមន៍ ដើម្បីជួយអោយពួកគេទទួលបានឱកាសសិក្សារៀនសូត្របន្ថែម ឱកាសការងារ ក៏ដូចជាឱកាសផ្ទាល់ខ្លួនផងដែរ។

អ្នកស្ម័គ្រចិត្តផ្នែកអប់រំភាសាអង់គ្លេសបង្រៀននៅតាមវិទ្យាល័យ និងសាលាគរុកោសល្យ ។ ដូចដែលបានស្នើសុំដោយក្រសួងអប់រំ យុវជន និងកីឡា អ្នកស្ម័គ្រចិត្តបង្រៀនរួមគ្នាជាមួយគ្រូជនជាតិខ្មែរ។ ការធ្វើបែបនេះមិនត្រឹមតែផ្តល់ផលប្រយោជន៍ដល់សិស្សានុសិស្សប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយបង្កើនសមត្ថភាពភាសារបស់គ្រូបង្រៀន ព្រមទាំងបង្កើនជំនាញបច្ចេកទេសគ្រប់គ្រងថ្នាក់រៀនរបស់ពួកគេផងដែរ។ តាមរយៈការបង្រៀនជាមួយគ្រូជនជាតិខ្មែរ អ្នកស្ម័គ្រចិត្តអាចចែករំលែកវិធីសាស្ត្រក្នុងការបង្រៀនបែបទំនើប ជួយរៀបចំនិងបង្រៀនមេរៀន បង្កើនជំនាញភាសាអង់គ្លេសសម្រាប់ការប្រាស្រ័យទាក់ទង និងណែនាំអោយស្គាល់ពីបច្ចេកទេសផ្សេងៗក្នុងការគ្រប់គ្រងថ្នាក់រៀនអោយមានប្រសិទ្ធភាព។

អ្នកស្ម័គ្រចិត្តក៏បង្កើត និងបង្កើនធនធានសម្រាប់ការរៀនសូត្រ និងការបង្រៀនផងដែរដែលរួមមានដូចជាការណែនាំនូវបច្ចេកវិទ្យាថ្មីៗ។ តាំងពីឆ្នាំ២០០៧ មានអ្នកស្ម័គ្រចិត្តផ្នែកអប់រំភាសាអង់គ្លេសចំនួន៣៦៥នាក់ បានបំពេញការងារស្ម័គ្រចិត្តនៅប្រទេសកម្ពុជា។

## គោលដៅរបស់គម្រោង៖

- ▲ បង្កើនវិធីសាស្ត្របង្រៀន
- ▲ បង្កើនភាពជោគជ័យរបស់សិស្ស

## សកម្មភាពរបស់គម្រោង៖

- ▲ បង្រៀនរួមគ្នាជាមួយគ្រូដៃគូជាជនជាតិខ្មែរក្នុងថ្នាក់រៀន
- ▲ បង្កើតកិច្ចតែងការបង្រៀន និងសម្ភារៈបង្រៀន ដែលប្រើប្រាស់វិធីសាស្ត្រទំនាក់ទំនងក្នុងការបង្រៀនភាសាអង់គ្លេស
- ▲ សម្របសម្រួលសកម្មភាពសិក្សាក្រៅម៉ោងរបស់សិស្សានុសិស្ស និងបង្កើតក្លឹបសិក្សា
- ▲ បង្កើតបណ្ណាល័យ និងមណ្ឌលធនធានសំរាប់ការសិក្សា

# សមិទ្ធផលសម្រេចបានក្នុងឆ្នាំ ២០១៧

## គោលដៅទី ១៖ បង្កើនវិធីសាស្ត្របង្រៀន

សាស្ត្រាចារ្យនឹងបង្កើនចំណេះដឹងផ្នែកភាសាអង់គ្លេស និងអនុវត្តវិធីសាស្ត្របង្រៀនបែបសិស្សមជ្ឈមណ្ឌល។

### បង្កើនវិធីសាស្ត្របង្រៀនបែបសិស្សមជ្ឈមណ្ឌលដល់សាស្ត្រាចារ្យ

**៧៣%**
ចំនួនគ្រូដែលបានបង្កើនការប្រើប្រាស់បច្ចេកទេសថ្មីៗរបស់ពួកគេក្នុងការបង្រៀនសិស្ស។

**៥៤%**
ចំនួនគ្រូដែលបានបង្កើនការយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងថ្នាក់រៀនអោយកាន់តែមានប្រសិទ្ធភាព។

**៤៧%**
ចំនួនគ្រូដែលបានបង្កើនការប្រើប្រាស់ការវាយតម្លៃថ្នាក់រៀនដែលមានមូលដ្ឋានរបស់ខ្លួនក្នុងការតាមដាន និងព័ត៌មានវឌ្ឍនភាពរបស់សិស្ស។

### បង្កើនភាពស្ទាត់ជំនាញខាងទំនាក់ទំនងជាភាសាអង់គ្លេសដល់សាស្ត្រាចារ្យ

**៦៧%**
ចំនួនគ្រូដែលបានបង្កើនការប្រើប្រាស់បច្ចេកទេសថ្មីៗ សម្រាប់ការបង្រៀនភាសាអង់គ្លេស។

**៥១%**
ចំនួនគ្រូដែលបានបង្កើនការចូលរួមរបស់ពួកគេនៅក្នុងសកម្មភាពអភិវឌ្ឍន៍វិជ្ជាជីវៈគ្រូបង្រៀនជាភាសាអង់គ្លេស។

**៦៧%**
ចំនួនគ្រូដែលបានបង្កើនការប្រើប្រាស់ភាសាអង់គ្លេសនៅពេលបង្រៀនក្នុងថ្នាក់។

### បង្កើនវិធីសាស្ត្របង្រៀនដល់គរុសិស្ស

**៤៨**
ចំនួនគរុសិស្សដែលបង្កើនវិធីបង្រៀនសិស្សបែបមជ្ឈមណ្ឌល។

**១២៨**
ចំនួនគរុសិស្សដែលបង្កើនជំនាញភាសាអង់គ្លេសរបស់ពួកគេយ៉ាងហោចណាស់ ១០% ដោយការវាយតម្លៃតាមឧបករណ៍វាយតម្លៃជាផ្លូវការ។

**៧៨**
ចំនួនគរុសិស្សដែលបានបង្កើតអោយប្រសើរឡើងឬគ្រប់គ្រងសម្ភារៈឧបទេសដូចជា ផ្ទាំងរូបភាព ឯកសារ កិច្ចតែងការ ឬសម្ភារៈដែលគាំទ្រការសិក្សាថ្នាក់រៀនផ្សេងទៀត។

## គោលដៅទី ២៖ បង្កើនភាពជោគជ័យដល់សិស្ស

សិស្សានុសិស្ស ឬយុវជន នឹងបង្កើនសមត្ថភាពភាសាអង់គ្លេស និងអភិវឌ្ឍជំនាញលើភាពជាអ្នកដឹកនាំតាមរយៈការសិក្សាភាសាអង់គ្លេសតាមកម្មវិធីរបស់ក្រសួងអប់រំ យុវជន និងកីឡា និងកម្មវិធីសិក្សាបន្ថែម។

### បង្កើនចំណេះដឹងសិស្សតាមរយៈការចូលរួមសកម្មភាពផ្សេងៗ និងផ្តល់ជំនាញភាពជាអ្នកដឹកនាំតាមរយៈកម្មវិធីសិក្សាបន្ថែម

**១,២៩៣**
ចំនួនសិស្សដែលបានបង្ហាញភាពជាអ្នកដឹកនាំនៅក្នុងថ្នាក់និងក្រៅថ្នាក់តាមរយៈសកម្មភាពដូចជាការបង្រៀនពីមិត្តភក្តិ ឬ ធ្វើលំហាត់ជំនួយបន្ថែម។

### បង្កើនចំណេះដឹងរបស់សិស្សតាមរយៈការចូលរួមសកម្មភាពសិក្សាក្នុងថ្នាក់

**៤,២២៥**
ចំនួនសិស្សដែលបានបង្ហាញពីការកើនឡើងនូវចំណេះដឹងភាសាអង់គ្លេស ។

**៣,០២៥**
ចំនួនសិស្សដែលបានបង្កើន/បង្ហាញពីការជឿជាក់លើខ្លួនឯង និងការលើកទឹកចិត្តខ្លួនតាមរយៈការចូលរួមសកម្មភាពក្នុងថ្នាក់ក្លឹបសិក្សាតូចៗតាមសាលា ឬ បោះជំរំសិក្សា។

### ពង្រីកការប្រើប្រាស់បណ្ណាល័យនិង/ឬការប្រើប្រាស់ និងធនធានបច្ចេកវិទ្យាទំនាក់ទំនង និងពត៌មានវិទ្យា (ICT)

**៤,៤២០**
ចំនួនសិស្ស ដែលបានចូលប្រើប្រាស់បណ្ណាល័យដើម្បីអាន ឬ ប្រើប្រាស់ធនធានបច្ចេកវិទ្យា ឬធនធានផ្សេងៗទៀត។

# ដំណើររឿងជោគជ័យលើផ្នែកអប់រំភាសាអង់គ្លេស

## បណ្ណាល័យសាលារៀន

*អ្នកស្ម័គ្រចិត្ត ខេត វិធិននើ និងអ្នកគ្រូ ឡូន ប៊ុននី*
*ខេត្តកំពង់ឆ្នាំង*



*ខេត និង ប៊ុន្នី បង្រៀនសិស្សអំពីរបៀបប្រើប្រាស់បណ្ណាល័យ*

នៅភាគខាងជើងរាជធានីភ្នំពេញ នៅជិតទន្លេសាប គឺជាស្រុកសាមគ្គីមានជ័យនៃខេត្តកំពង់ឆ្នាំង ដែលនៅទីនោះវិទ្យាល័យមិត្តភាព បានផ្តល់សេវាអប់រំដល់ភូមិនៅជនបទចំនួនប្រមាណជាង ២០ ភូមិ។ ឆ្នាំនេះ វិទ្យាល័យមិត្តភាព បានបង្កើតបណ្ណាល័យ និងកន្លែងសម្រាប់សិក្សាថ្មីមួយ។ អ្នកគ្រូ លូន ប៊ុននី ដែលជាគ្រូបង្រៀនភាសាអង់គ្លេសម្នាក់នៅវិទ្យាល័យ បានដឹកនាំគម្រោងនេះជាមួយអ្នកស្ម័គ្រចិត្តភីសខ័រម្នាក់ឈ្មោះ ខេត (Kate) ដោយសារគាត់ជឿជាក់យ៉ាងខ្លាំងលើសារៈសំខាន់នៃអក្ខរភាព និងតម្រូវការរបស់សិស្សក្នុងការអានសៀវភៅ និងឯកសារនានា។ អ្នកគ្រូ ប៊ុននី ពុំធ្លាប់បានធ្វើការជាមួយបរទេសទេពីមុនមក ហើយបើទោះបីជាដំបូងគាត់មានការខ្មាសអៀនបន្តិចក៏ពិតមែន ប៉ុន្តែគាត់ចង់ធ្វើឲ្យក្តីសុបិន្តដែលមានបណ្ណាល័យមួយបើកដំណើរការក្លាយជាការពិតសម្រាប់វិទ្យាល័យមិត្តភាព តាមរយៈការធ្វើការជាមួយនឹង ខេត។

នៅមុនពេលគម្រោងនេះចាប់ផ្តើម វិទ្យាល័យមិត្តភាព មានកន្លែងមួយសម្រាប់ទុកធ្វើជាបណ្ណាល័យ ប៉ុន្តែកន្លែងនេះពុំសូវបានប្រើប្រាស់នោះទេ និងរក្សាទុកសៀវភៅ និងឯកសារតិចតួចប៉ុណ្ណោះ។ ខេត និងអ្នកគ្រូ ប៊ុននី បានរួមគ្នាបង្កើតចក្ខុវិស័យបណ្ណាល័យមួយ ដែលនឹងធ្វើឲ្យសិស្សានុសិស្សអាចចូលអានសៀវភៅបាននិងផ្តល់នូវកន្លែងដែលមានសុវត្ថិភាពសម្រាប់សិស្សានុសិស្សសិក្សារៀនសូត្រ និងពង្រីកចំណេះដឹងរបស់ពួកគេ។

> *“ការអប់រំ គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ និងអាចផ្លាស់ប្តូរពិភពលោកបាន ហើយបណ្ណាល័យនេះនឹងជួយឲ្យសិស្សានុសិស្សរបស់យើងទទួលបានការអប់រំកាន់តែល្អប្រសើរ។*
> *– ប៊ុននី”*

បន្ទាប់ពីបានចំណាយពេលជាច្រើនខែក្នុងការធ្វើផែនការយ៉ាងយកចិត្តទុកដាក់ជាមួយនាយកសាលា បុណ្ណារក្ស និងសមាជិកសហគមន៍ជាច្រើនរូប បណ្ណាល័យនេះបច្ចុប្បន្នមានសៀវភៅកើនឡើងច្រើនជាងមុនបីដង ទាំងជាភាសាអង់គ្លេស និងជាភាសាខ្មែរ។ មានតុថ្មីៗនិងធំជាងមុន និងមានក្តាខៀនសម្រាប់សិស្សរៀនអានដោយខ្លួនឯង។ ការរៀបចំបើកឲ្យដំណើរការបណ្ណាល័យនេះ គឺជាក្តីរំភើបរីករាយបំផុតមួយក្នុងចំណោមលោកគ្រូអ្នកគ្រូ និងសិស្សានុសិស្ស។ បច្ចុប្បន្ន បណ្ណាល័យនេះនៅបន្តបើកដំណើរការដដែលនៅថ្ងៃសិក្សា ហើយតែងមានសិស្សចូលអានពេញៗ ដោយពួកគេរីករាយនឹងការអាន និងការស្រាវជ្រាវអំពីសៀវភៅថ្មីៗ បន្ថែមលើនេះ ខេត និងអ្នកគ្រូ ប៊ុននី បច្ចុប្បន្ននេះបានបើកកិច្ចប្រជុំក្លឹបសិក្សាភាសាអង់គ្លេសប្រចាំសប្តាហ៍នៅក្នុងបណ្ណាល័យថ្មីនេះ។ សាលារៀនមានទីតាំងស្ថិតនៅកណ្តាលស្រុក ដែលធ្វើឲ្យវាមានភាពងាយស្រួលសម្រាប់សិស្សចេញចូលនៅពេលដែលពួកគេទំនេរ។ ដោយសារតែការបើកដំណើរការជាផ្លូវការនៃបណ្ណាល័យនេះ ខេត និងអ្នកគ្រូ ប៊ុននីបានសង្កេតឃើញថាមានចំនួនសិស្សកាន់តែច្រើនឡើងនាំគ្នាមកអានសៀវភៅ ហើយចំនួនសិស្សកាន់តែច្រើនឡើងបានចូលរួមក្នុងក្លឹបសិក្សាភាសាអង់គ្លេសរបស់ពួកគាត់។

ទំនាក់ទំនងដ៏រឹងមាំរវាង ខេត និងអ្នកគ្រូ ប៊ុននី បានធ្វើឲ្យគម្រោងនេះសម្រេចបានដោយជោគជ័យ។ ចាប់តាំងពីដំណាក់កាលដំបូងនៃការធ្វើផែនការរហូតដល់ការអនុវត្តគម្រោង ខេត និងអ្នកគ្រូ ប៊ុននី បានធ្វើការងាររួមគ្នាដើម្បីធានាថាគោលដៅដើម្បីលើកកម្ពស់ការអប់រំនៅវិទ្យាល័យមិត្តភាពអាចសម្រេចទៅបានដោយជោគជ័យ។ អ្នកគ្រូ ប៊ុននី ជឿជាក់ថា ការងាររបស់គាត់ជាមួយ ខេត មិនត្រឹមតែផ្តល់បទពិសោធន៍ល្អៗប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ឲ្យគាត់នូវ “ទំនុកចិត្តយ៉ាងខ្លាំងសម្រាប់អនាគតរបស់គាត់”។



*សិស្សានុសិស្សត្រេកអរដែលមានបណ្ណាល័យនិងសៀវភៅច្រើនសម្រាប់អាន*

# ដំណើររឿងជោគជ័យលើផ្នែកអប់រំភាសាអង់គ្លេស

## តើអ្នកចង់ធ្វើអ្វីនៅពេលដែលអ្នកធំឡើង?

*អ្នកស្ម័គ្រចិត្ត ហាយមិន ណាំ និងលោកគ្រូ ខន ស៊ាងហួរ*
*ខេត្តត្បូងឃ្មុំ*

"តើអ្នកចង់ធ្វើអ្វីនៅពេលអ្នកធំឡើង?" - នេះជាសំណួរមួយដែលតែងសាកសួរសិស្សញឹកញាប់ ប៉ុន្តែជាសំណួរពិបាកមួយសម្រាប់សិស្សឆ្លើយ។

ចម្លើយស្រដៀងៗគ្នាដែលអ្នកស្ម័គ្រចិត្តភីសខ័រ ឈ្មោះ ហាយមិន (Hyemin) តែងស្តាប់ឮពីសិស្សរបស់គាត់នៅវិទ្យាល័យដំបែរក្នុងខេត្តត្បូងឃ្មុំគឺ ពួកគេចង់ធ្វើជាគ្រូបង្រៀន។ បន្ទាប់ពីបានស្តាប់ឮចម្លើយនេះពីសិស្សស្ទើរគ្រប់គ្នាហាយមិន បានសាកសួរគ្រូដៃគូរបស់គាត់គឺលោកគ្រូ ស៊ាងហួរ ថាហេតុអ្វីបានជាសិស្សចង់ក្លាយជាគ្រូបង្រៀន។ លោកគ្រូ សេងហួរ បានឆ្លើយតបយ៉ាងងាយថា "នេះគឺជាការងារតែមួយគត់ដែលពួកគេស្គាល់"។

> *ខ្ញុំធ្វើការងារដោយក្តីស្រឡាញ់។ នេះជាសហគមន៍និងជាប្រទេសរបស់ខ្ញុំ។ ខ្ញុំសូមកោតសរសើរចំពោះអ្នក ដែលអ្នកស្រឡាញ់សហគមន៍និងប្រទេសរបស់ខ្ញុំ។ ខ្ញុំពិតជាសប្បាយចិត្តដែលយើងអាចចែករំលែកចំណេះដឹងរួមគ្នាបាន។*
> *– ស៊ាងហួរ*

នៅពេលស្តាប់ឮបែបនេះ ហាយមិន និងលោកគ្រូ ស៊ាងហួរ បានប្តេជ្ញាចិត្តដើម្បីពង្រីកទស្សនៈយល់ឃើញរបស់សិស្សចំពោះឱកាសការងារនាពេលអនាគត។ ហាយមិន នៅចងចាំអំពីពិពរណ៌ការងារជាច្រើនដែលគាត់ធ្លាប់បានចូលរួមក្នុងពេលដែលគាត់នៅជាសិស្សនៅឡើយ ហើយការចូលរួមក្នុងពិពរណ៌ការងារទាំងនោះបានជួយឲ្យគាត់ឲ្យពង្រីកក្តីស្រម៉ៃរបស់គាត់កាត់ធំជាងមុន។ ហាយមិន បានចែករំលែកបទពិសោធន៍និងគំនិតនេះជាមួយលោកគ្រូ សេងហួរ ហើយគាត់ចង់សាកល្បងបង្កើតបទពិសោធន៍ស្រដៀងគ្នានេះសម្រាប់សិស្សរបស់ពួកគាត់។ ហាយមិន ស្នើសុំឲ្យមានការអញ្ជើញបុគ្គលនានាពីសហគមន៍ដែលមានការងារខុសៗគ្នា ហើយលោកគ្រូ ស៊ាងហួរបានយកគំនិតនេះទៅពង្រីកបន្ថែមដោយស្នើសុំឲ្យមានអញ្ជើញអតីតសិស្សពីវិទ្យាល័យរបស់គាត់ដើម្បីបង្ហាញដល់សិស្សានុសិស្សថា ពួកគេអាចធ្វើការងារបានដូចជាសិស្សច្បងរបស់ពួកគេដែរ។ លោកគ្រូ សេងហួរ គឺជាអតីតសិស្សជំនាន់ទីមួយដែលបានបញ្ចប់ការសិក្សានៅវិទ្យាល័យដំបែរ ដែលបានធ្វើឲ្យគាត់ក្លាយជាមនុស្សសំខាន់មួយនៅក្នុងសហគមន៍នេះ។ លោកគ្រូ ស៊ាងហួរបានទំនាក់ទំនងជាមួយមិត្តភ័ក្តិរបស់គាត់ និងអតីតសិស្សដើម្បីអញ្ជើញពួកគេឲ្យចែករំលែកបទពិសោធន៍នៅក្នុងពិពរណ៌ការងារនៅវិទ្យាល័យដំបែរ។



*ហាយមិន ចូលរួមប្រជុំជាមួយសិស្សានុសិស្សទាំងអស់*

ពិពរណ៌ការងារ ប្រារព្ធឡើងនៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៨ ដោយមានសិស្សចូលរួមចំនួន ១៥០នាក់។ មានវាគ្មិនសរុបចំនួន ១០ រូប ដែលមានអាជីពការងារផ្សេងៗគ្នារាប់ចាប់តាំងពីគ្រូបង្រៀន នាយកសាលា វេជ្ជបណ្ឌិត ធនាគារិក មន្ត្រីរដ្ឋាភិបាលមកពីក្រសួងកិច្ចការនារី រហូតដល់មន្ត្រីគយ។ អតីតសិស្សម្នាក់ៗ បានចំណាយពេលចូលរួមក្នុងព្រឹត្តិការណ៍នេះ និងបាននិយាយអំពីបទពិសោធន៍របស់ពួកគេក្នុងនាមជាអតីតសិស្សមួយរូបនៃវិទ្យាល័យដំបែរ ចែករំលែកអំពីទម្លាប់នៃការសិក្សារបស់ពួកគេ ដំណើរការនៃការទទួលបានអាជីពការងាររបស់ពួកគេ និងបានលើកទឹកចិត្តឲ្យសិស្សបង្កើតទម្លាប់ល្អក្នុងអានសៀវភៅ។ អតីតសិស្ស ក៏បានសម្រេចចិត្តរួមគ្នាធ្វើការប្រមូលប្រាក់ដើម្បីទិញសៀវភៅ និងប៊ិកសម្រាប់ចែកជូនដល់សិស្សដែលបានមកចូលរួមក្នុងពិពរណ៌ការងារនោះផងដែរ។

អំឡុងពេលនៃចែករំលែកបទពិសោធន៍របស់វាគ្មិននីមួយៗ ឃើញច្បាស់ថា ពួកគេពិតជាមានការពេញចិត្ត និងមានក្តីសប្បាយរីករាយក្នុងការចែករំលែកបទពិសោធន៍របស់ពួកគេជាមួយសិស្សានុសិស្សទាំងនោះ។ ពេលវេលាពិសេសមួយក្នុងអំឡុងពេលនៃព្រឹត្តិការណ៍នេះ គឺនៅពេលដែលវាគ្មិនជាស្ត្រីតែមួយរូបគត់បានលើកទឹកចិត្តឲ្យសិស្សស្រីបន្តការសិក្សារបស់ពួកគេ មិនថាអ្នកដទៃនិយាយយ៉ាងណាចំពោះពួកគេនោះទេ។ គាត់បានបញ្ជាក់ថា យើងអាចបន្តការសិក្សា និងទទួលបានការងារធ្វើទោះបីយើងជាស្ត្រីក៏ដោយ។ គាត់បានពន្យល់ថាគាត់ក៏អាចទទួលបានការងារមួយបន្ទាប់ពីគាត់រៀបការរួចផងដែរ ដូចនេះពុំមានការចាំបាច់ត្រូវធ្វើតាមពាក្យសម្តីរបស់នរណាម្នាក់ទោះទេ។

ហាយមិន ពិតជាមានការលើកទឹកចិត្តយ៉ាងខ្លាំង ដែលមានអតីតសិស្សជាច្រើនបានចូលរួមក្នុងព្រឹត្តិការណ៍នេះ និងពិតជាអរគុណយ៉ាងខ្លាំងចំពោះលោកគ្រូ ស៊ាងហួរ សម្រាប់ភាពរីករាយ និងភាពជាអ្នកដឹកនាំក្នុងការរៀបចំពិពរណ៌ការងារនេះ។ បើទោះបីជាមានពេលខ្លះជួបការពិបាកខ្លាំង មិនអាចស្តាប់គ្នាយល់ក៏ដោយ ប៉ុន្តែ ហាយមិននិងលោកគ្រូ ស៊ាងហួរ បានបង្កើតនូវទំនាក់ទំនងចំណេះដឹងថ្មីៗសម្រាប់ការផ្លាស់ប្តូរជាវិជ្ជមាននៅពេលអនាគតនៅក្នុងសហគមន៍ និងវិទ្យាល័យរបស់ពួកគេ តាមរយៈកិច្ចសហប្រតិបត្តិការរបស់ពួកគេ និងការប្តេជ្ញាចិត្តរួមគ្នាដើម្បីលើកកម្ពស់ជីវិតរស់នៅរបស់សិស្សានុសិស្សរបស់ពួកគេ។



*ការប្រជុំក្នុងសាលារៀនជាមួយសិស្សានុសិស្សទាំងអស់*

# សកម្មភាពប្រចាំថ្ងៃរបស់

*បង្រៀនភាសាអង់គ្លេស ក្លឹបសិក្សាភាសាអង់គ្លេស លើកកម្ពស់ស្ត្រី អប់រំសុខភាពសហគមន៍*













# កស្ម័គ្រចិត្តពីសខ័រកម្ពុជា

*៍ វាស់សញ្ញាជីវិត ក្លឹបសិល្បៈ កសាងទំនាក់ទំនងជាមួយសហគមន៍ និងសកម្មភាពច្រើនទៀត*



























# ការអប់រំសុខភាពសហគមន៍

នៅឆ្នាំ ២០០៩ ដោយសារមានការស្នើសុំពីក្រសួងសុខាភិបាល ភ្នាក់ងារ ភីសខ័រប្រចាំនៅកម្ពុជាបានពង្រីកសកម្មភាពរបស់ខ្លួនដោយការចាប់ផ្តើមគម្រោងអប់រំសុខភាពសហគមន៍ ។ គោលបំណងនៃគម្រោងនេះដើម្បីជួយសហគមន៍ និងប្រជាជនកម្ពុជា ជាពិសេសស្ត្រីនិងកុមារក្នុងការលើកកម្ពស់សុខភាពនិងសុខុមាលភាពទូទៅក៏ដូចជាការបង្កើនសមត្ថភាពរបស់ពួកគេដើម្បីដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងសុខភាព។ អ្នកស្ម័គ្រចិត្តភីសខ័រធ្វើការជាមួយបុគ្គលិកមណ្ឌលសុខភាព ក្រុមទ្រទ្រង់សុខភាពភូមិ និងសាលារៀនផ្សេងៗដើម្បីកសាងសមត្ថភាពរបស់ប្រជាជនក្នុងសហគមន៍អោយចេះឆ្លើយតបនឹងតម្រូវការផ្នែកសុខភាពរបស់ពួកគេ។មានអ្នកស្ម័គ្រចិត្តផ្នែកអប់រំសុខភាពចំនួន២០៨នាក់បានបំពេញការងារតាំងពីឆ្នាំ២០១០មកម្លេះ។

## គោលដៅរបស់គម្រោង៖

- ▲ សុខភាពមាតា និង កុមារ
- ▲ ការប្រព្រឹត្តដែលនាំឲ្យមានសុខភាពល្អ

## សកម្មភាពរបស់គម្រោង៖

- ▲ ធ្វើការអប់រំសុខភាពនៅមណ្ឌលសុខភាពសហគមន៍ និងតាមរយៈការចុះតាមផ្ទះ
- ▲ លើកកម្ពស់ការអនុវត្តអាហារូបត្ថម្ភជាវិជ្ជមានតាមរយៈសួនបន្លែតាមផ្ទះនិងសហគមន៍ និងការបង្ហាញពីការចំអិននិងផ្តល់អាហារដល់កូន
- ▲ លើកកម្ពស់ការពិនិត្យសុខភាពម្តាយមុននិងក្រោយពេលសម្រាល ការចាក់ថ្នាំបង្ការ និងការធ្វើផែនការគ្រួសារនៅទូទាំងសហគមន៍
- ▲ អប់រំប្រជាជនក្នុងសហគមន៍អំពីបញ្ហាអនាម័យនិងទឹកស្អាត ដូចជាការលាងដៃអោយបានត្រឹមត្រូវ ការទប់ស្កាត់និងការព្យាបាលជម្ងឺរាគរូស ការបាត់បង់ជាតិទឹក និងការព្យាបាលដែលសមស្រប ក៏ដូចជាការរក្សាទុកទឹកស្អាតផងដែរ
- ▲ ដឹកនាំប្រជាជនអោយចូលរួមក្នុងសកម្មភាពផ្សេងៗ ដូចជាការធ្វើលំហាត់ប្រាណជាក្រុម ការបង្ហាញពីការចំអិនអាហារដែលនាំអោយមានសុខភាពល្អ ពត៌មានអំពីការប្រឆាំងនឹងការជក់បារី និង យុទ្ធនាការបង្កើនការយល់ដឹងអំពីគ្រឿងស្រវឹង និងថ្នាំញៀន
- ▲ អប់រំប្រជាជនក្នុងសហគមន៍អំពីសុខភាពបន្តពូជ

# សមិទ្ធផលសម្រេចបានក្នុងឆ្នាំ ២០១៧

## គោលដៅទី ១៖ សុខភាពមាតា និង កុមារ

ប្រជាជនក្នុងសហគមន៍នឹងបង្កើនចំណេះដឹង និងជំនាញ និងទទួលយកនូវការអនុវត្តន៍ល្អក្នុងការថែទាំសុខភាព មាតា និងទារក។

### ការពិនិត្យផ្ទៃពោះមុនសម្រាល និងការសម្រាលកូន

**៤,៧១២**
ចំនួនម្តាយមានផ្ទៃពោះបានទទួលការអប់រំអំពីសារៈសំខាន់នៃការពិនិត្យផ្ទៃពោះ ការថែទាំក្រោយសម្រាល ការចាក់ថ្នាំបង្ការ ផែនការគ្រួសារ និង ការសម្រាលកូន។

**១,៥១០**
ចំនួនស្ត្រីដែលដឹងយ៉ាងហោច៤ ឬច្រើននៃសញ្ញាគ្រោះថ្នាក់អំឡុងពេលមានផ្ទៃពោះ ហើយដែលត្រូវទៅរកការសង្គ្រោះជាបន្ទាន់ពីគ្រូពេទ្យ។

**៨៥០**
ចំនួនប្រជាពលរដ្ឋដែលបានរៀនជាបុគ្គល ឬជាក្រុម អំពីមធ្យោបាយពន្យារកំណើត។

**១,១១៦**
ចំនួនស្ត្រីដែលមានកូនអាយុក្រោម១២ខែ ប្រាប់ថាគាត់បានទៅពិនិត្យផ្ទៃពោះ៤ដង ឬច្រើនជាងបួនដងអំឡុងពេលមានផ្ទៃពោះ។

### អាហារូបត្ថម្ភ

**១០,២៤៤**
ចំនួនមនុស្សដែលបានទទួលការអប់រំអំពីសុខភាពកុមារ និងអាហារូបត្ថម្ភ តាមរយៈកម្មវិធីសុខភាពដែលទ្រទ្រង់ដោយរដ្ឋាភិបាលអាមេរិក។

**៦,៨១៩**
ចំនួនអាណាព្យាបាល ឬស្ត្រីដែលបានទទួលការអប់រំពីអ្នកស្ម័គ្រចិត្ត ឬដៃគូដែលបានរកឃើញសកម្មភាពមួយ ឬក៏ច្រើនជាងមួយដើម្បីបង្ការគ្រួសារមិនឲ្យកង្វះអាហារូបត្ថម្ភ។

**៣,២៧១**
ចំនួនកុមារដែលមានអាយុពី៦ដល់ ៥៩ខែ មានប័ណ្ណសុខភាពដែលបានថ្លឹងទម្ងន់យ៉ាងហោចបានមួយដងកាលពី៣ខែមុន។

**៧៣%**
ចំនួនស្ត្រីដែលបង្ហាញថាពួកគេចេះអំពីរបៀបរៀបចំចំអិនអាហារបំប៉នសម្រាប់កុមារបានត្រឹមត្រូវ។

**៨៨%**
ចំនួនគ្រួសារដែលត្រូវបានបណ្តុះប័ណ្តាលដោយអ្នកស្ម័គ្រចិត្តបានរាយការណ៍ថាទទួលបានអាហារស្រស់ៗក្នុងរយៈពេល៦ខែបន្ទាប់ពីបានធ្វើសួនបន្លែ។

**៣,៥២៧**
ចំនួនប្រជាជនដែលបានទទួលការបណ្តុះបណ្តាលដោយអ្នកស្ម័គ្រចិត្តអំពីការបំបៅដោះកូនដោយទឹកដោះម្តាយ។

### អនាម័យ និង ទឹកស្អាត

**៦០**
ចំនួនមនុស្សដែលអាចបង្ហាញថាពួកគាត់ចេះពីរបៀបធ្វើឲ្យទឹកស្អាតសម្រាប់ប្រើប្រាស់។

**៥២៦**
ចំនួនមនុស្សដែលបានរៀន/ទទួលការអប់រំអំពីរបៀបធ្វើឲ្យទឹកស្អាតនិងរក្សាទុកដាក់ទឹកសម្រាប់ផឹកនិង សម្រាប់ដាំស្លបានត្រឹមត្រូវ។

**៧,២៣៧**
ចំនួនមនុស្សដែលស្គាល់ពេលវេលាសំខាន់៣ ឬអាចច្រើនជាង៣ដែលពួកគាត់ត្រូវលាងសម្អាតដៃ។

**២៤១**
ចំនួនគ្រួសារដែលបានបង្រៀនដោយអ្នកស្ម័គ្រចិត្តបានរាយការណ៍ថាបានសាងសង់កន្លែងលាងដៃក្រោយការបណ្តុះបណ្តាល។

## គោលដៅទី ២៖ ការប្រព្រឹត្តដែលនាំឲ្យមានសុខភាពល្អ

ប្រជាពលរដ្ឋក្នុងសហគមន៍នឹងបានរីកចម្រើនកាន់តែប្រសើរថែមទៀត នូវបំណិនជីវិត ហើយនឹងប្រព្រឹត្តទៅតាមទម្លាប់ដែលនាំមកនូវសុខភាពល្អ។

### ជម្ងឺមិនឆ្លង

**១០,៩៩២**
ចំនួនមនុស្សដែលបានទទួលការអប់រំអំពីជម្ងឺមិនឆ្លង និង ការកាត់បន្ថយកត្តាដែលនាំឲ្យមានគ្រោះថ្នាក់។

**២,៥២៤**
ចំនួនមនុស្សដែលបានទទួលការអប់រំអំពីភាពគ្រោះថ្នាក់នៃការផឹកស្រា និង ការប្រើប្រាស់សារធាតុញៀនផ្សេងៗ។

**៧,៤០៤**
ចំនួនមនុស្សពេញវ័យ ដែលបានទទួលការអប់រំ អំពីរបបអាហារប្រចាំថ្ងៃ ដែលមានសារៈសំខាន់សម្រាប់សុខភាព។

**២,៥៥០**
ចំនួនមនុស្សដែលទទួលការអប់រំអំពីកត្តាបង្កគ្រោះថ្នាក់នៃជម្ងឺឆ្លងដែលទាក់ទងនឹងការប្រើប្រាស់ថ្នាំជក់ និងអំពីការឈប់ប្រើប្រាស់ថ្នាំជក់។

**៤៥៨**
ចំនួនដងនៃការហាត់ប្រាណ ដែលរៀបចំដោយអ្នកស្ម័គ្រចិត្តភ្នាក់ងារ ភីសខ័រ និង ដៃគូការងារ។

**៤,១៦១**
ចំនួនមនុស្សអាចរកឃើញពីវិធីហាត់ប្រាណ២ ឬច្រើនយ៉ាង ដើម្បីឲ្យក្លាយជាទម្លាប់ប្រចាំថ្ងៃរបស់ពួកគេ។

### សុខភាពបន្តពូជ

**៧៦៨**
ចំនួនមនុស្សដែលដឹងពីវិធីយ៉ាងតិចពីរអំពីការការពារកុំអោយមានផ្ទៃពោះ ឬការពារកុំអោយឆ្លងជម្ងឺកាមរោគ។

**៥៩**
ចំនួនមនុស្សដែលចេះពីរបៀបប្រើប្រាស់ស្រោមអនាម័យបានយ៉ាងត្រឹមត្រូវ។

# ដំណើររឿងជោគជ័យលើផ្នែកអប់រំសុខភាព

## មាតាដែលមានសុខភាពល្អ

*អ្នកស្ម័គ្រចិត្ត ហេលី ខេស និងអ្នកគ្រូ គាវ មនោរម្យ*
*ខេត្តសៀមរាប*



*ហេលី និង មនោរម្យ ចុះផ្តល់ការអប់រំដល់ប្រជាជនក្នុងសហគមន៍*

"តើអ្នកបានរៀនសូត្រអំពីបញ្ហានេះពីមុនមកដែរឬទេ?"អ្នកគ្រូពេទ្យ មនោរម្យ (ពេទ្យឆ្មបនៅមណ្ឌលសុខភាពក្នុងមូលដ្ឋាន) បានសួរសំណួរនេះ។

អ្នកស្ម័គ្រចិត្តសុខភាពភូមិចំនួន ២១ រូប មកពីឃុំសៀមរាប បានងក់ក្បាលរួមគ្នា នៅពេលពិនិត្យមើលដ្យាក្រាមនៃស្បែរម៉ាតូសូអ៊ីតនៅក្នុងស៊ុតនៅក្នុងដៃស្បូន។ ក្រុមអ្នកដឹកនាំសុខភាពមិត្តរួមក្រុមកំពុងសិក្សាស្វែងយល់អំពីចំណេះដឹងមូលដ្ឋាននៃជីវវិទ្យាបន្តពូជជាលើកដំបូង។ អ្នកស្ម័គ្រចិត្តសុខភាពភូមិ ទទួលបានការបណ្តុះបណ្តាលឲ្យធ្វើការផ្សព្វផ្សាយពីការពន្យារកំណើតដែលមានប្រសិទ្ធភាពរយៈពេលយូរ និងការប្រើប្រាស់កន្លែងសម្រាករង់ចាំការសម្រាលកូនសម្រាប់ស្ត្រីមានផ្ទៃពោះ។ ក្នុងអំឡុងពេលនៃសិក្ខាសាលានេះ អ្នកគ្រូពេទ្យ មនោរម្យបានផ្សព្វផ្សាយអំពីការសម្រាលនៅតាមមណ្ឌលសុខភាព និងការថែទាំសុខភាពពេលមានផ្ទៃពោះ ដោយលុបបំបាត់នូវជំនឿមិនសមហេតុផលអំពីការពន្យារកំណើត និងបានត្រួតពិនិត្យឡើងវិញនូវសញ្ញាគ្រោះថ្នាក់ក្នុងអំឡុងពេលនៃការមានផ្ទៃពោះ។ រួមគ្នាជាមួយនឹងអ្នកស្ម័គ្រចិត្តភីសខ័រ ឈ្មោះ ហេលី (Haley) អ្នកគ្រូពេទ្យ មនោរម្យ បានដឹកនាំគម្រោងនេះដោយមានគោលដៅក្នុងការបង្កើតសហគមន៍មួយដែលមានកំណើតមានសុវត្ថិភាព តាមការគ្រោងទុក និងមានសុខភាពល្អ។

បន្ទាប់ពីកិច្ចសន្ទនាដំបូងនៅមណ្ឌលសុខភាពដែលដឹកនាំដោយប្រធានឆ្មប ឈ្មោះពេទ្យ សំ ហេលី និងអ្នកគ្រូពេទ្យ មនោរម្យ បានធ្វើការសម្ភាសជាមួយស្ត្រីចំនួន ៩៦ នាក់នៅទូទាំងភូមិចំនួនដប់បី ដើម្បីទទួលបានការយល់ដឹងឲ្យបានច្បាស់អំពីចំណុចអាទិភាពរបស់សហគមន៍នៅផ្នែកសុខភាពមាតា។ ទាំងម្តាយទើបមានបុត្រថ្មីៗ និងស្ត្រីដែលមានកូនច្រើនបង្ហាញពីតម្រូវការក្នុងការទទួលបានកន្លែងសម្រាលដែលមានលក្ខណៈល្អប្រសើរនៅក្នុងមណ្ឌលសុខភាពក្នុងមូលដ្ឋាន និងពង្រីកគម្លាតនៃការមានកូន។ ការដែលមិនមានទីកន្លែងសមស្របសម្រាប់ស្នាក់នៅក្នុងមណ្ឌលសុខភាពក្នុងមូលដ្ឋាន ធ្វើឲ្យស្ត្រីជាច្រើនជ្រើសរើសទៅសម្រាលកូនរបស់ពួកគេនៅមន្ទីរពេទ្យឯកទេសនៅក្នុងខេត្តដែលមានចម្ងាយឆ្ងាយជាជាងសម្រាលនៅក្នុងមណ្ឌលសុខភាពតាមមូលដ្ឋាន ស្ត្រី ក៏បង្ហាញពីបញ្ហាលំបាកក្នុងការគ្រប់គ្រងនិងចាត់ចែងលើទំហំគ្រួសាររបស់ពួកគេផងដែរ។ ស្ត្រីខ្លះ បានបង្ហាញថាខ្លួនចង់ទទួលបានការពន្យារកំណើតរយៈពេលវែង ដោយសារពួកគេពុំមានមធ្យោបាយធ្វើដំណើរទៅកាន់មណ្ឌលសុខភាព ដែលធ្វើឲ្យមានការលំបាកនៅក្នុងការការជ្រើសរើសយកវិធីពន្យារកំណើតរយៈពេលខ្លី ដូចជាថ្នាំពន្យារកំណើត និងថ្នាំចាក់ជាដើម។

អ្នកគ្រូពេទ្យ មនោរម្យ ជឿជាក់ថា "ការពន្យារកំណើត និងការសម្រាលកូន គឺជារឿងពីរនៃបញ្ហាតែមួយ"។ បុគ្គលិក មណ្ឌលសុខភាព ទទួលស្គាល់ពីការលំបាករបស់ស្ត្រីនៅក្នុងមូលដ្ឋាន។ ពួកគេខិតខំប្រឹងប្រែងពង្រីកសមត្ថភាពនៃការយល់ដឹងរបស់ពួកគេ ដើម្បីផ្តល់នូវតម្រូវការសុខភាពនៃស្ត្រីតាមរយៈការធ្វើផែនការនិងការអនុវត្តគម្រោងមួយដើម្បីបង្កើតនូវកន្លែងសម្រាករង់ចាំសម្រាលកូនសម្រាប់ស្ត្រីមានផ្ទៃពោះ ជាកន្លែងដែលស្ត្រីសម្រាកនៅមុនពេលសម្រាលបុត្រថ្មី និងរួមបញ្ចូលទាំងវគ្គផ្សព្វផ្សាយពីសុខភាពបន្តពូជមាតា ដែលដឹកនាំដោយអ្នកស្ម័គ្រចិត្តសុខភាពភូមិដែលទទួលបានការបណ្តុះបណ្តាល។ បន្ទាប់ពីការបណ្តុះបណ្តាលដូចបានរៀបពីខាងដើម អ្នកស្ម័គ្រចិត្តសុខភាពភូមិ មានអារម្មណ៍ថាខ្លួនមានចំណេះដឹងច្រើនជាងមុនដើម្បីពិភាក្សាអំពីប្រធានបទសុខភាពជាមួយស្ត្រីនៅក្នុងភូមិរបស់ពួកគេ។ ដោយសារភាពជាអ្នកដឹកនាំរបស់អ្នកគ្រូពេទ្យ មនោរម្យ និងការប្តេជ្ញាចិត្តរបស់អ្នកស្ម័គ្រចិត្តភូមិក្នុងមូលដ្ឋាន ទើបធ្វើឲ្យឃុំដូនកែវបច្ចុប្បន្ននេះក្លាយជាកន្លែងដែលមានសុខភាពល្អសម្រាប់ស្ត្រីនិងម្តាយស្នាក់នៅ។



*ហេលី និង មនោរម្យ ចុះផ្តល់ការអប់រំដល់ស្ត្រីក្នុងសហគមន៍*

# ដំណើររឿងជោគជ័យលើផ្នែកអប់រំសុខភាព

## សួនបន្លែនៅសាលារៀន

*អ្នកស្ម័គ្រចិត្ត ប្រាយអ៊ិន គីម និងលោកនាយក កែវ សារ៉ែន*
*ខេត្តព្រៃវែង*

សាលាបឋមសិក្សាពាមរក៏ ដែលមានទីតាំងនៅតាមបណ្តោយទន្លេមេគង្គនៅក្នុងខេត្តព្រៃវែង ជាសាលាមួយដែលមានចំណាត់ថ្នាក់ល្អជាងគេក្នុងចំណោមសាលារៀននានានៅក្នុងខេត្តទាំងមូល។ សាលារៀននេះបានអប់រំសិស្សច្រើនជាង ៥៣០នាក់ មកពីភូមិច្រើនជាង ៥ នៅជុំវិញទីនោះ ហើយគឺជាសាលារៀនមួយដែលបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការផ្តល់ការអប់រំនៅថ្នាក់បឋមសិក្សាដល់កូនសិស្សនៅក្នុងមូលដ្ឋាន។ ភាពជោគជ័យក្នុងពេលបច្ចុប្បន្នរបស់សាលារៀនពុំបានធ្វើឲ្យលោកនាយក កែវ សារ៉ែន បញ្ឈប់ការស្វះស្វែងរកនូវមធ្យោបាយដើម្បីធ្វើការកែលម្អសាលារៀនរបស់គាត់ និងការកែលម្អគុណភាពអប់រំដែលសិស្សទទួលបាននោះទេ។

> *ខ្ញុំជឿជាក់ថា វាពិតជាមានសារៈសំខាន់ណាស់ក្នុងការបន្តលើកកម្ពស់គុណភាពសាលារៀនរបស់យើង ដើម្បីឲ្យយើងអាចធ្វើឲ្យជីវភាពនិងចំណេះដឹងរបស់សិស្សយើងមានលក្ខណៈល្អប្រសើរជាងមុន។*
>
> *–កែវ សារ៉ែន*

អ្នកស្ម័គ្រចិត្តភីសខ័រ លោក ប្រាយអ៊ិន (Brian) បានធ្វើការជាមួយលោកនាយក សារ៉ែន ដើម្បីរៀនភាសាខ្មែរចាប់តាំងពីគាត់បានមកដល់ពាមរក៏ជាលើកដំបូងមកម្ល៉េះ។ជាចុងក្រោយ វគ្គបង្រៀនរបស់ពួកគេបានប្រែក្លាយទៅជាកិច្ចពិភាក្សាអំពីអ្វីដែលពួកគេអាចធ្វើបានដើម្បីលើកកម្ពស់គុណភាពនៃការបង្រៀននៅសាលាបឋមសិក្សា។ នៅក្នុងខែកក្កដា ឆ្នាំ២០១៨ ពួកគេបានរៀបចំកិច្ចប្រជុំជាច្រើនជាមួយគ្រូបង្រៀន និងឪពុកម្តាយសិស្សនៅសាលារៀន ដើម្បីកំណត់ពីតម្រូវការអាទិភាពរបស់សាលារៀន និងសហគមន៍សាលារៀន។ តាមរយៈកិច្ចប្រជុំទាំងនេះមានការលើកឡើងអំពីក្តីបារម្ភអំពីទម្លាប់មិនល្អនៃការទទួលទានអាហាររបស់សិស្ស។ ឪពុកម្តាយជាច្រើនបានកត់សម្គាល់ថា កូនចៅរបស់ពួកគេចង់ទទួលទានចំណីអាហារកញ្ចប់ជាជាងជ្រើសរើសទទួលទានបន្លែ ដើម្បីធ្វើឲ្យមានសុខភាពល្អ និងរក្សាតុល្យភាពចំណីអាហារ។

ការពិភាក្សាគ្នាជាបន្តបន្ទាប់រវាងលោកនាយក សារ៉ែន និង ប្រាយអ៊ិន បានឈានទៅដល់គំនិតនៃការអនុវត្តសួនបន្លែនៅតាមសាលារៀន ជាមួយនឹងការកែលម្អកម្មវិធីសិក្សាផ្នែកអាហារូបត្ថម្ភ។ ប្រាយអ៊ិន និង សារ៉ែន មានទំនុកចិត្តក្នុងការអនុវត្តគម្រោង នេះបន្ទាប់ពីពួកគេបានចូលរួមនៅក្នុងការបណ្តុះបណ្តាលអំពី សន្តិសុខស្បៀងរបស់ភ្នាក់ងារភីសខ័រ



ប្រាយអ៊ិន និងលោកគ្រូសារ៉ែន និងកូនសិស្សកំពុងរៀបចំធ្វើសួនបន្លែ

រួមគ្នានៅក្នុងខែមីនា ឆ្នាំ២០១៨ដែលនៅក្នុងការបណ្តុះបណ្តាលនេះ អ្នកទាំងពីរបានរៀនអំពីបច្ចេកទេសនានាដូចជាការផលិតជីកំប៉ុស និងថែទាំសួនបន្លែជាដើម។ ប្រាយអ៊ិន និងសារ៉ែន ជឿថាសួនបន្លែសាលា នឹងក្លាយជាឱកាសល្អមួយសម្រាប់សិស្សមានម្ចាស់ការលើការអនុវត្តការទទួលទានអាហាររបស់ពួកគេ។អ្នកទាំងពីរបានរួមគ្នាធ្វើសេចក្តីព្រាង និងបានដាក់បញ្ជូនសំណើសុំថវិកាតាមរយៈភ្នាក់ងារភីសខ័រ ដើម្បីទទួលបានមូលនិធិដំបូងដើម្បីគាំទ្រដល់សួនបន្លែ និងការអនុវត្តកម្មវិធីសិក្សានេះ។

ចាប់តាំងពីដើមឆ្នាំសិក្សាថ្មីនៅក្នុងឆ្នាំ២០១៨-២០១៩ មក លោកនាយក សារ៉ែន និង ប្រាយអ៊ិន បានធ្វើការងាររួមគ្នាដើម្បីចាត់ចែងនិងរៀបចំក្លាសាលានានានៅសាលារៀនដើម្បីអប់រំសិស្ស ១៨០ នាក់ និងគ្រូបង្រៀនចំនួន ៦ រូបអំពីការធ្វើសួនបន្លែ និងអាហារូបត្ថម្ភ។ លោកគ្រូ សារ៉ែន បានដើរតួនាទីជាកម្លាំងជំរុញដ៏សំខាន់នៅពីក្រោយការធ្វើគម្រោងសួនបន្លែនេះ ដែលបានដឹកនាំវគ្គសិក្សាលម្អិតផ្អែកទៅតាមឯកសារដែលគាត់បានរៀននៅក្នុងវគ្គសិក្សាអំពីសន្តិសុខស្បៀងខាងលើ។ សាលារៀន បានចូលរួមក្នុងការថែទាំសួនបន្លែ និងបន្តការអប់រំអាហារូបត្ថម្ភនៅតាមសាលារៀនជារៀងរាល់ឆ្នាំសិក្សានីមួយៗ។

> *ខ្ញុំគិតថា វាជាការល្អសម្រាប់គ្រូបង្រៀននិងសិស្សានុសិស្សរបស់យើងក្នុងការសិក្សាអំពីការធ្វើសួនបន្លែនេះ ដោយសារវាគឺជាជំនាញដែលពួកគេអាចប្រើប្រាស់បាននៅក្រៅថ្នាក់រៀនរបស់ពួកគេ។*
>
> *–កែវ សារ៉ែន*



សកម្មភាពកូនសិស្សធ្វើរងដាំបន្លែ

# គម្រោងអភិវឌ្ឍន៍ដឹកនាំដោយសហគមន៍

ការផ្តោតជាសំខាន់នៃការងាររបស់អ្នកស្ម័គ្រចិត្ត គឺដើម្បីកសាងសមត្ថភាពប្រជាជនដែលពួកគេធ្វើការងារជាមួយ។ ខណៈដែលអ្នកស្ម័គ្រចិត្តផ្តោតជាសំខាន់លើបំណែងចែកការងាររបស់ពួកគេនៅលើការបង្រៀនភាសាអង់គ្លេស និងការបណ្តុះបណ្តាលគ្រូបង្រៀន និងការអប់រំសុខភាពសហគមន៍ ពួកគេក៏បានធ្វើការជាមួយភាគីដៃគូដែលទទួលបានការចាត់តាំងនិងសមាជិកសហគមន៍ដទៃផ្សេងទៀតដើម្បីគាំទ្រគម្រោងអប់រំនៅមធ្យមសិក្សាដែលជំរុញដោយសហគមន៍។

គម្រោងទាំងនេះ ផ្តោតជាសំខាន់លើចំណុចជាច្រើន រួមទាំងសុខភាពមាតានិងទារក ទឹកស្អាត អនាម័យ សន្តិសុខស្បៀងអាហារូបត្ថម្ភ ការអភិវឌ្ឍយុវជននិងភាពជាអ្នកដឹកនាំ ការអភិវឌ្ឍធនធានសហគមន៍ ឬតម្រូវការផ្សេងទៀតរបស់សហគមន៍ និងឱកាសនានាដែលកំណត់ដោយសហគមន៍ដែលអ្នកស្ម័គ្រចិត្តត្រូវបានដាក់ឲ្យបម្រើការ។ អ្នកស្ម័គ្រចិត្តទទួលបានការបណ្តុះបណ្តាលឲ្យប្រើប្រាស់ឧបករណ៍វិភាគសហគមន៍ចូលរួម ដែលជួយដល់សមាជិកសហគមន៍ក្នុងការកំណត់ និងផ្តល់អាទិភាពដល់តម្រូវការរបស់ពួកគេ។ ការយល់ដឹងអំពីតម្រូវការជាអាទិភាពនេះផ្តល់ព័ត៌មានដល់គម្រោងអំពីចំណុច/គំនិតដែលអាចចូលរួមចំណែកដល់ការអភិវឌ្ឍនិងសុខុមាលភាពសហគមន៍នៅក្នុងចំណោមប្រជាជនទូទៅ ឬប្រជាជនគោលដៅនៅក្នុងសហគមន៍ ដូចជាកុមារ យុវជន ស្ត្រី គ្រូបង្រៀន ។ល។

នៅពេលដែលគំនិតអំពីគម្រោងត្រូវបានកំណត់ និងមានការឯកភាពគ្នា អ្នកស្ម័គ្រចិត្តនិងសមាជិកសហគមន៍ ទទួលបានការបណ្តុះបណ្តាលរយៈពេល ៣ ថ្ងៃនៅក្នុងរៀបចំនិងការគ្រប់គ្រងគម្រោង។ តាមរយៈការសិក្សានេះ ពួកគេត្រឡប់ទៅសហគមន៍វិញជាមួយសមាជិកសហគមន៍ដទៃផ្សេងទៀត ដោយពួកគេបានរៀបចំក្របខណ្ឌគម្រោង និងផែនការអភិវឌ្ឍដែលរួមមាន៖ គោលដៅគម្រោង កម្មវត្ថុ ការកំណត់ធនធានសហគមន៍ ការកំណត់ធនធានដែលត្រូវការ តួនាទីនិងទំនួលខុសត្រូវនៃសមាជិកសហគមន៍ចូលរួម ថវិកា និងការគ្រប់គ្រងនិងការវាយតម្លៃផែនការ។ តាមរយៈកិច្ចដំណើរការនេះ គំនិតអ្វីមួយអាចក្លាយទៅជាការពិតបាន ហើយសហគមន៍អាចរួមគ្នាអភិវឌ្ឍសម្រាប់ជាប្រយោជន៍ដល់មនុស្សគ្រប់គ្នា។

គម្រោងខ្លះ អាចអនុវត្តបានដោយប្រើប្រាស់ធនធានដែលមានស្រាប់។ គម្រោងខ្លះទៀត អាចត្រូវការឲ្យមានសកម្មភាពរៃអង្គាសប្រាក់ដឹកនាំដោយសហគមន៍ ដើម្បីបន្តអនុវត្តគម្រោងទៅមុខទៀត។ គម្រោងផ្សេងទៀត អាចតម្រូវឲ្យមានធនធានសេដ្ឋកិច្ចបន្ថែម ហើយអ្នកស្ម័គ្រចិត្តអាចគាំទ្រដល់សមាជិកសហគមន៍នៅក្នុងការដាក់ស្នើសុំមូលនិធិពីធនធានក្នុងស្រុក ជាតិ និងអន្តរជាតិ។ នៅគ្រប់ករណីទាំងអស់ គោលដៅចុងក្រោយគឺដើម្បីសម្រេចបានតាមតម្រូវការរបស់សហគមន៍ ហើយក្នុងពេលជាមួយគ្នានោះត្រូវកសាងសមត្ថភាពប្រជាពលរដ្ឋដែលពាក់ព័ន្ធ ទទួលបាននូវការផ្តល់អំណាច និងអាចអនុវត្តគម្រោងនេះជាថ្មីម្តងទៀតក្នុងពេលអនាគត ដើម្បីអភិវឌ្ឍសហគមន៍របស់ពួកគេ និងដើម្បីបំពេញតាមតម្រូវការផ្ទាល់ខ្លួនរបស់ពួកគេ។

អំឡុងការិយបរិច្ឆេទឆ្នាំ ២០១៨ គម្រោងដឹកនាំដោយសហគមន៍ដែលទទួលបានការគាំទ្រពីអ្នកស្ម័គ្រចិត្តភីសខ័របានជួយកសាងសមត្ថភាពនៃអ្នកផ្តល់សេវាជនជាតិខ្មែរច្រើនជាង ១,៦៧១ នាក់នៅក្នុងផ្នែកសុខាភិបាល និងការអប់រំនៅទូទាំងខេត្តចំនួន ១៩។ គម្រោងទាំងអស់នេះបានផ្សព្វផ្សាយទៅដល់ប្រជាជនដែលទទួលប្រយោជន៍ប្រមាណ ៦៥,០៧៦នាក់ ដែលគុណភាពជីវិតរបស់ពួកគេត្រូវបានកែលម្អតាមរយៈសមត្ថភាពរបស់ពួកគេក្នុងការចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តសហគមន៍ និងការអភិវឌ្ឍសហគមន៍។



អ្នកស្ម័គ្រចិត្ត លា និងកន្លែងលាងដៃដែលនាងបានសាងសង់



កូនសិស្សប្រើប្រាស់បណ្ណាល័យ

## អនាម័យទឹកស្អាត និងសុខុមាលភាព (WASH)

គម្រោង គម្រោងទឹកស្អាត និងអនាម័យ (WASH) មានគោលបំណងក្នុងការកាត់បន្ថយគ្រោះថ្នាក់នៃជំងឺបង្កឡើងពីទឹកនៅក្នុងសហគមន៍ ដែលនាំឲ្យសមាជិកសហគមន៍មានសុខភាពល្អ និងមានអាយុវែង។

- ▲ គម្រោងដឹកនាំដោយសហគមន៍ដែលគាំទ្រដោយអ្នកស្ម័គ្រចិត្តភីសខ័រ បានធ្វើឲ្យប្រសើរឡើងនូវស្ថានភាពអនាម័យនៅក្នុងសហគមន៍ តាមរយៈការសាងសង់បរិក្ខារអនាម័យ និងការអប់រំលើប្រធានបទមួយចំនួនដូចជាការលាងសម្អាតដៃ ការធ្វើប្រព្រឹត្តិកម្មទឹកនិងការរក្សាទុកទឹក និងផលប៉ះពាល់ធ្ងន់ធ្ងរនៃការបន្ទោបង់តាមទីវាល។
- ▲ ហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធសុខភាព ដូចជាកន្លែងលាងដៃ បង្គន់ និងធុងចម្រោះទឹក អាចនឹងត្រូវបានសាងសង់នៅតាមមណ្ឌលសុខភាព សាលារៀន និងនៅតាមគ្រួសារ។
- ▲ ប្រភពទឹកដែលអាចពឹងពាក់អាស្រ័យបាន អាចត្រូវបង្កើតឡើងតាមរយៈការជីកអណ្តូង និងអាងបាសាំងស្តុកទឹក។

### សមិទ្ធផល

- *បង្កើតប្រភពទឹក : ៦*
- *ស្តារបង្គន់ : ៣១*
- *សង់បង្គន់ថ្មី : ៣៦*
- *សាងសង់និងស្តារកន្លែងលាងដៃ : ៣៤*
- *ចែកចាយធុងចម្រោះទឹក : ១១៥*
- *កម្មភាពអប់រំកម្មវិធី WASH : ៦១*

# គម្រោងអភិវឌ្ឍន៍ដឹកនាំដោយសហគមន៍

## សួនបន្លែសម្រាប់អាហារូបត្ថម្ភ

គម្រោងសួនបន្លែ និងអាហារូបត្ថម្ភ មានគោលបំណងក្នុងការលើកកម្ពស់កម្រិតអាហារូបត្ថម្ភក្នុងចំណីអាហារ ដោយធ្វើការអប់រំប្រជាជនឲ្យធ្វើការផ្លាស់ប្តូររបបអាហារ និងដាំដុះបន្លែនិងផ្លែឈើដោយខ្លួនឯង។ អ្នកស្ម័គ្រចិត្តភីសខ័រ គាំទ្រដល់ការបង្កើតសួនបន្លែសហគមន៍នៅតាមមណ្ឌលសុខភាពនិងសាលារៀន សួនបន្លែគ្រួសារដើម្បីលើកកម្ពស់បរិមាណចំណីអាហារដែលទទួលទានដោយកុមារនិងមនុស្សពេញវ័យ។

- ▲ សួនបន្លែដែលបង្កើតឡើង និងថែរក្សាដោយសិស្សនិងគ្រូបង្រៀននៅតាមសាលារៀន ផ្តល់នូវឱកាសសម្រាប់ការសិក្សាដកពិសោធន៍ដែលជួយបំពេញបន្ថែមដល់ខ្លឹមសារម៉ោងសិក្សាថ្នាក់កសិកម្ម។ សិស្សនិងគ្រូបង្រៀនយកបន្លែនិងផ្លែឈើរបស់ពួកគេទៅផ្ទះដើម្បីលាយគ្នាទៅក្នុងមុខម្ហូបរបស់ពួកគេ។
- ▲ សួនបន្លែនៅតាមផ្ទះ ដែលត្រូវបានបង្កើតឡើងតាមរយៈគម្រោងនេះ បង្កើននូវពិពិធភាពនៃរបបអាហារនៅក្នុងគ្រួសារ និងជាកន្លែងសម្រាប់កែលម្អសុខភាពសមាជិកគ្រួសារ ជាពិសេសសម្រាប់កុមារអាយុក្រោមប្រាំឆ្នាំ។
- ▲ ការអនុវត្តកសិកម្មសរីរាង្គ ដូចជាការធ្វើកំប៉ុស និងការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតដែលគ្មានជាតិពុល អាចត្រូវបានដាក់បញ្ចូលទៅក្នុងការបណ្តុះបណ្តាលលើគម្រោងសួនបន្លែ ដើម្បីលើកកម្ពស់គុណតម្លៃអាហារូបត្ថម្ភនៃបន្លែនិងផ្លែឈើ។
- ▲ ការបង្ហាញពីការចម្អិនម្ហូបដោយប្រើប្រាស់បរិមាណដ៏ច្រើននៃផលិតផលដំណាំក្នុងសួនដែលល្អសម្រាប់សុខភាពជួយផ្លាស់ប្តូរទម្លាប់នៃការទទួលទានអាហារ និងបង្កើតគុណតម្លៃអាហារូបត្ថម្ភផ្នែកចំណីអាហារ។

| | | |
|---|---|---|
| សមិទ្ធផល | • សួនបន្លែក្នុងសហគមន៍បានបង្កើត | : ៣០ |

## ការអភិវឌ្ឍធនធានសាលា

គម្រោងអភិវឌ្ឍធនធាន ផ្តោតជាសំខាន់លើការលើកកម្ពស់ការអប់រំ តាមរយៈការទទួលបានធនធានសម្រាប់សិក្សា និងបញ្ចូលធនធានទាំងអស់នេះទៅក្នុងការសិក្សានៅក្នុងថ្នាក់រៀន។

- ▲ គម្រោងដឹកនាំដោយសហគមន៍ ដើម្បីធ្វើការកែលម្អនិងធ្វើឲ្យប្រសើរឡើងនូវមជ្ឈមណ្ឌលធនធាននៅតាមសាលារៀន ក៏ផ្តល់ជូននូវកន្លែងសម្រាប់បណ្តុះបណ្តាលគ្រូបង្រៀន និងបុគ្គលិកសាលា ដើម្បីប្រើប្រាស់ធនធានថ្មីប្រកបដោយប្រសិទ្ធភាព ដូចជា កុំព្យូទ័រ សៀវភៅ ម៉ាស៊ីនបញ្ចាំងស្លាយដ៍ អ៊ីនធឺណិត និងឯកសារសម្រាប់សិក្សារៀនសូត្រផ្សេងទៀត។
- ▲ ការកែលម្អបន្ទប់រៀន និងបណ្ណាល័យ បង្កើតបាននូវបរិយាកាសអំណោយផលសម្រាប់ការសិក្សារៀនសូត្រ។

| | | |
|---|---|---|
| សមិទ្ធផល | • ជួសជុលបណ្ណាល័យ | : ១៣ |
| | • ជួសជុលបន្ទប់កុំព្យូទ័រ | : ១ |

## ការអភិវឌ្ឍបំណិនជីវិតរបស់សិស្សនិងយុវជន

គម្រោងអភិវឌ្ឍបំណិនជីវិតសម្រាប់សិស្សនិងយុវជន ជាទូទៅតែងរួមបញ្ចូលនូវសកម្មភាពកសាងទំនុកចិត្ត ការអភិវឌ្ឍបំណិនភាពជាអ្នកដឹកនាំ សកម្មភាពផ្តោតសំខាន់លើការផ្លាស់ប្តូរអាកប្បកិរិយាពាក់ព័ន្ធនឹងការធ្វើការសម្រេចចិត្តដែលល្អសម្រាប់សុខភាព ការអប់រំអំពីសមភាពយេនឌ័រ ការធ្វើផែនការអនាគត និងសកម្មភាពកីឡាក្នុងចំណោមសកម្មភាពដទៃផ្សេងទៀត ដែលមានគោលដៅក្នុងការធ្វើឲ្យប្រសើរឡើងនូវបំណិនជីវិតជាទូទៅរបស់អ្នកចូលរួម។

- ▲ ក្លឹបជាច្រើនត្រូវបានបង្កើតឡើងជាកន្លែងដែលមានសុវត្ថិភាពសម្រាប់សិស្សនិងយុវជន ដើម្បីធ្វើការសិក្សារៀនសូត្រអំពីប្រធានបទជាច្រើនដែលសិស្សនិងយុវជនមានការចាប់អារម្មណ៍។ ក្លឹបជួបប្រជុំគ្នាជាប្រចាំក្នុងឆ្នាំសិក្សាទាំងមូល និងមានពេលក្នុងការដឹកនាំការអនុវត្តគម្រោងនៅតាមសហគមន៍របស់ពួកគេផ្ទាល់។
- ▲ ការបោះជំរុំ តែងធ្វើឡើងក្នុងរយៈពេលជាច្រើនថ្ងៃ។ ការបោះជំរុំអាចធ្វើឡើងនៅក្នុងសហគមន៍តែមួយ ឬដោយមានការចូលរួមពីផ្នែកដទៃផ្សេងទៀតនៅក្នុងខេត្ត។ ការបោះជំរុំ ត្រូវបានប្រើប្រាស់ជាមធ្យោបាយមួយដើម្បីបន្ថែមការអនុវត្តសកម្មភាពក្លឹប ឬជាព្រឹត្តិការណ៍ដំបូងសម្រាប់ក្លឹបថ្មីៗ។
- ▲ ការអប់រំមិត្តៈ ក្លឹបភាពអ្នកដឹកនាំ តែងតែចូលរួមនៅក្នុងការបណ្តុះបណ្តាលសិក្ខាកាម ដែលពួកគេអាចសិក្សាស្វែងយល់ពីចំណេះដឹងផ្អែកលើប្រធានបទ ជំនាញក្នុងការធ្វើបទបង្ហាញ និងរបៀបក្នុងការធ្វើផែនការវគ្គសិក្សាអប់រំគ្នាទៅវិញទៅមក។ សមាជិកនៃកម្មវិធីការអប់រំតាមរយៈមិត្តភ័ក្តិ បន្ទាប់មកត្រូវធ្វើការអប់រំនិងដឹកនាំមិត្តភ័ក្តិរបស់ពួកគេទៅលើប្រធានបទដែលពួកគេគិតថាមានសារៈសំខាន់ និងត្រូវការជាចាំបាច់។

| | | |
|---|---|---|
| សមិទ្ធផល | • បង្កើតក្លឹបសិក្សា | : ១៣៦ |
| | • បោះជំរុំសិក្សា | : ២០ |
| | • ក្រុមមិត្តអប់រំមិត្ត | : ១៦ |

# ដំណើររឿងជោគជ័យលើផ្នែកគម្រោងអភិវឌ្ឍន៍ដឹកនាំដោយសហគមន៍

## ស្ត្រីជាមាសទឹកដប់

*អ្នកស្ម័គ្រចិត្ត អាលី ហ្វីលីប និង លោក អ៊ុំ សារ៉ាន*
*ខេត្តកំពត*

"មនុស្សប្រុសជាមាសទឹកដប់ មនុស្សស្រីជាក្រណាត់ស។" នេះគឺជាសុភាសិតមួយក្នុងចំណោមសុភាសិតខ្មែរជាច្រើនទៀតដែលចាត់ទុកមនុស្សប្រុសថាមានតម្លៃខ្ពស់ ហើយតម្លៃនោះមិនចេះប្រែប្រួល។ ចំណែកឯស្ត្រីនិងកេរ្តិ៍ឈ្មោះរបស់ខ្លួនអាចខូចខាតដោយងាយ ហើយពេលណាខូចខាតហើយគឺខូចជារៀងរហូត។ ពាក្យទាំងអស់នេះ ក៏មានសមត្ថភាពជះឥទ្ធិពលដល់ក្មេងស្រី និងផ្លូវចិត្តរបស់ស្ត្រីខ្មែរពាក់ព័ន្ធនឹងតម្លៃផ្ទាល់ខ្លួន និងមហិច្ឆតានាពេលអនាគត។ អ្នកស្ម័គ្រចិត្តពីសខ៊ី ឈ្មោះ អាលី ហ្វីលីប (Alli Phillips) និងដៃគូរបស់នាង បានមើលឃើញពីតម្រូវការក្នុងការផ្តល់អំណាចដល់ស្ត្រីនិងធ្វើការប្រឆាំងនឹងសុភាសិតនេះ និងបទដ្ឋានសង្គម តាមរយៈការបង្កើត "សិក្ខាសាលាស្តីពីស្ត្រីជាមាសទឹកដប់" និងគម្រោងបន្ទប់ទឹក។

អាលី និងដៃគូនៅក្នុងមូលដ្ឋាន បានបង្កើតនិងចែកចាយការស្ទង់មតិទៅដល់សិស្សស្រីដែលកំពុងសិក្សានៅថ្នាក់ទី ១០ រហូតដល់ថ្នាក់ទី ១២ នៅវិទ្យាល័យក្នុងសហគមន៍។ ការស្ទង់មតិនេះ បានធ្វើការត្រួតពិនិត្យនិងលើកឡើងពីបញ្ហាបទដ្ឋានយេនឌ័រ សារៈសំខាន់នៃការអប់រំ ការជំរុញលើកទឹកចិត្តការងារ និងសមត្ថភាពក្នុងការគ្រប់គ្រងរដូវឲ្យបានត្រឹមត្រូវ និងការធ្វើអនាម័យល្អនៅវិទ្យាល័យក្នុងមូលដ្ឋាន។

ការវាយតម្លៃការឆ្លើយតបនឹងការស្ទង់មតិនេះ អាលី និង ដៃគូរបស់នាង អាចអង្កេតឃើញពីគម្លាតចំណេះដឹង និងកំណត់បានពីផ្នែកនៃផលប្រយោជន៍រួម។ ដោយប្រើប្រាស់ព័ត៌មានដែលប្រមូលបាន សិក្ខាសាលា "ស្ត្រីជាមាសទឹកដប់" ត្រូវបានរៀបចំ និងធ្វើផែនការ។ ក្នុងអំឡុងពេលនៃការរៀបចំសិក្ខាសាលាចំនួនប្រាំលើក អាលី មិត្តរួមការងារ និងវាគ្មិនកិត្តិយសបានបើកកិច្ចពិភាក្សា និងដឹកនាំសិក្ខាសាលាស្តីពីជំនាញភាពជាអ្នកដឹកនាំ ការធ្វើផែនការអាជីពការងារ សុខភាពស្ត្រី ការកំណត់គោលដៅ និងសារៈសំខាន់នៃទស្សនៈអំពីរូបរាងកាយ និងតម្លៃផ្ទាល់ខ្លួន។ សិក្ខាសាលាទាំងនេះ

> *សិក្ខាសាលា "ស្ត្រីជាមាសទឹកដប់" ត្រូវបានបង្កើតនិងរៀបចំឡើងដើម្បីអាចអនុវត្តឡើងវិញបាន និងប្រកបដោយនិរន្តរភាព។*
>
> *–អាលី ហ្វីលីប*

ផ្តល់ជូន និងបណ្តុះនូវទំនុកចិត្តនិងជំនាញភាពជាអ្នកដឹកនាំដល់ស្ត្រីវ័យក្មេងនៅក្នុងសហគមន៍ និងបានផ្តល់ជូនដល់ពួកគេនូវមធ្យោបាយចាំបាច់ដើម្បីដើរតាមគន្លងមាគ៌ាដ៏ជោគជ័យនិងល្អប្រសើរ ឆ្ពោះទៅរកជីវិតរស់នៅរបស់ពួកគេក្នុងនាមជាមនុស្សពេញវ័យ។ការស្ទង់មតិក៏បង្ហាញផងដែរថា ជាង ៧០% នៃសិស្សដែលបានស្ទង់មតិនេះ មានអារម្មណ៍ថាពួកគេពុំមានបរិក្ខារត្រឹមត្រូវនៅលើបរិវេណសាលារៀនដើម្បីគ្រប់គ្រងការមករដូវឲ្យបានត្រឹមត្រូវនោះទេ។ នេះបាននាំឲ្យពួកគេមានអារម្មណ៍ស្រេស និងមានអារម្មណ៍រំខានពេញមួយថ្ងៃសិក្សាតែម្តង។ បន្ទាប់ពីការពិភាក្សានិងការប្រជុំស្តីពីមតិយោបល់ពីសិស្សស្រី និងនាយកសាលានិងបុគ្គលិកសិក្សា គម្រោងនេះបានផ្តល់មូលនិធិសាងសង់បន្ទប់ទឹកថ្មីដែលល្អសម្រាប់សិស្សស្រី និងបន្ទប់ប្តូរសម្លៀកបំពាក់ដែលគាំទ្រឲ្យមាននូវបរិយាកាសងាយស្រួលនៅតាមសាលា។ បន្ទប់ទឹកទាំងនេះ ផ្តល់នូវកន្លែងសុវត្ថិភាព និងអនាម័យដល់ស្ត្រីច្រើនជាង ៥០០ នាក់។

អាលី និងដៃគូនៅក្នុងមូលដ្ឋាន
គឺមានទំនុកចិត្តដែលសិក្ខាសាលានេះ នឹងបន្តនៅក្នុងភូមិក្នុងនាមជាមធ្យោបាយដែលមានស្ថេរភាពដើម្បីគាំទ្រដល់ការផ្តល់អំណាចដល់ស្ត្រីនៅក្នុងភូមិនិងសហគមន៍នៅជុំវិញ។



*សិស្សានុសិស្សចូលរួមសិក្ខាសាលាទទួលបានវិញ្ញាបនប័ត្របញ្ជាក់ការសិក្សា*

# ដំណើររឿងជោគជ័យលើផ្នែកគម្រោងអភិវឌ្ឍន៍ ដឹកនាំដោយសហគមន៍

## មណ្ឌលធនធានសម្រាប់សិក្សា

*អ្នកស្ម័គ្រចិត្ត នីកូឡាស វេបប៊ឺត និងលោកគ្រូ ទិត្យ ភឿន*
*ខេត្តកំពត*

បច្ចុប្បន្ននេះ មានសិស្សអនុវិទ្យាល័យច្រើន ១,៣០០ នាក់ និងគ្រូបង្រៀន ៩៨ នាក់នៅក្នុងខេត្តកំពង់ឆ្នាំង ទទួលបានកន្លែងសម្រាប់ការអប់រំ ប្រើប្រាស់អ៊ីនធឺណិតដោយសុវត្ថិភាព និងផ្តល់កិច្ចសហការដល់គម្រោងនេះ។ គំនិតសម្រាប់គម្រោងទទួលបានមកពីសិស្សានុសិស្សនិងគ្រូបង្រៀនខ្លួនឯងផ្ទាល់ ដែលបានចូលរួមក្នុងសកម្មភាពវាយតម្លៃដើម្បីជួយអ្នកស្ម័គ្រចិត្តភីសខ័រ លោក នីកូឡាស (Nicholas) និងសហដៃគូរបស់គាត់លោក ភឿន ឲ្យមានការយល់ដឹងអំពីតម្រូវការអទិភាពនៃសាលារៀនរបស់ពួកគេ។ នីកូឡាស និង ភឿន បានចូលរួមនៅក្នុងសហគមន៍សាលារៀននៅក្នុងគម្រោងនេះចាប់តាំងពីដើមទីមក ដែលនាំឲ្យមានភាពម្ចាស់នៅក្នុងសហគមន៍រាប់ចាប់តាំងពីនាយកសាលា គ្រូបង្រៀន និងរហូតដល់សិស្សានុសិស្ស។



*នីកូឡាស និងលោកគ្រូ ភឿន ទិញកុំព្យូទ័រសម្រាប់បណ្ណាល័យ*

គម្រោងនេះ បានបង្កើតនូវទីតាំងបើកចំហធំទូលាយមួយសម្រាប់សិស្សានុសិស្សប្រើជាប្រចាំថ្ងៃ ដោយបង្រួមបន្ទប់រៀនចំនួនពីរបញ្ចូលគ្នា។ មានការផ្តល់ជូនកុំព្យូទ័រចំនួនប្រាំគ្រឿង ហើយកុំព្យូទ័រ ២០ គ្រឿងទៀតត្រូវបានជួសជុល និងធ្វើការដំឡើងប្រព័ន្ធដំណើរការថ្មី។ កុំព្យូទ័រទាំងអស់នេះបច្ចុប្បន្ន ត្រូវបានភ្ជាប់ទៅនឹងបណ្តាញអ៊ីនធឺណិត។បណ្ណារក្សចំនួនបីរូប និងគ្រូបង្រៀនផ្នែកបច្ចេកវិទ្យាព័ត៌មានចំនួនពីររូបទទួលបានការបណ្តុះបណ្តាលនៅក្នុងការគ្រប់គ្រងធនធាន និងអំពីរបៀបក្នុងការបង្រៀនសិស្សក្នុងសរសេរប្រវត្តិរូប និងស្រាវជ្រាវនៅលើអ៊ីនធឺណិតដោយសុវត្ថិភាព។ សិស្សថ្នាក់ទី ១២ ទាំងអស់ នឹងចូលរួមក្នុងសិក្ខាសាលាស្តីពីការសរសេរប្រវត្តិរូប ជារៀងរាល់ឆ្នាំ ហើយសិស្សានុសិស្សនៅគ្រប់កម្រិតថ្នាក់ទាំងអស់ បានបញ្ចប់ថ្នាក់ស្រាវជ្រាវនៅលើអ៊ីនធឺណិតដោយសុវត្ថិភាព។

តាមរយៈការចូលរួមចំណែកពីសហគមន៍ និងការទិញសៀវភៅថ្មីៗ ទើបមានធនធានថ្មីៗច្រើនជាង ៥០០ អាចប្រើប្រាស់បាន។ មជ្ឈមណ្ឌលធនធានសិក្សា បានបង្កើតឱកាសស្មើគ្នាសម្រាប់សិស្ស និងគ្រូបង្រៀនគ្រប់រូបក្នុងការប្រើប្រាស់បច្ចេកវិទ្យានិងធនធានអនឡាញថ្មីៗ។ បន្ថែមលើនេះ ការប្តេជ្ញាចិត្តរបស់នាយកសាលាដើម្បីសម្រេចបានជោគជ័យដល់មជ្ឈមណ្ឌលធនធានសិក្សា នាំទៅដល់ការបង្កើតម៉ោងសិក្សាមួយម៉ោងក្នុងមួយសប្តាហ៍សម្រាប់ថ្នាក់នីមួយៗនៅក្នុងមជ្ឈមណ្ឌលធនធាន។

ភឿន និង នីកូឡាស បានសហការគ្នានៅលើការរៀបចំគម្រោង និងការអនុវត្តគម្រោង ដោយរួមគ្នាបង្កើតវគ្គបណ្តុះបណ្តាល និងការគ្រប់គ្រងពេលវេលាគម្រោង និងមូលនិធិជាប្រចាំថ្ងៃ។ ភាពជោគជ័យពិតប្រាកដនៃគម្រោងនេះ គឺកើតចេញដោយសកម្មភាពក្លៀវក្លានិងការប្តេជ្ញាចិត្តពីសហគមន៍សាលារៀនទាំងមូលនៅគ្រប់ដំណាក់កាលនៃការអនុវត្តការងារ និងការប្តេជ្ញាចិត្តរបស់ពួកគេដើម្បីធានានូវនិរន្តរភាព និងការរីកលូតលាស់នៃមជ្ឈមណ្ឌលធនធានសិក្សា។បច្ចុប្បន្ននេះ សិស្សានុសិស្សនៅក្នុងសហគមន៍ទទួលបានការអប់រំដែលមានគុណភាពខ្ពស់ និងមានឱកាសល្អប្រសើរសម្រាប់អនាគត។



*សិស្សានុសិស្សប្រើប្រាស់កុំព្យូទ័រក្នុងបណ្ណាល័យ*

# បទពិសោធន៍រស់នៅជាមួយគ្រួសារខ្មែរ

## សេចក្តីស្រលាញ់ធ្វើអោយអ្នកក្លាយជាគ្រួសារតែមួយ

ដោយ៖ អ្នកស្ម័គ្រចិត្ត ដានីញែល វ៉ាហ្វូសាល្វ



ដានីញែល និងគ្រួសារខ្មែររបស់គាត់

ធ្លាប់បានអានសុភាសិតមួយដែលនិយាយថា "យើងជាប់ទំនាក់ទំនងគ្នាដោយសារសាច់ឈាម។ ក្តីស្រឡាញ់ធ្វើឲ្យយើងក្លាយជាគ្រួសារ។" តាមរយៈបទពិសោធន៍របស់ខ្ញុំជាមួយភ្នាក់ងារភីសខ័រ ខ្ញុំសង្ឃឹមថានឹងមានទំនាក់ទំនងល្អជាមួយគ្រួសារម្ចាស់ផ្ទះ។ ខ្ញុំពិតជាមានការភ័យខ្លាចអំពីអ្វីដែលនឹងអាចកើតមានឡើងនៅក្នុងពេលប៉ុន្មានខែខាងមុខក្នុងនាមជាអ្នកស្ម័គ្រចិត្តម្នាក់ ជាមនុស្សចំណូលថ្មីនៅក្នុងភូមិរបស់ខ្ញុំ និងនៅក្នុងគ្រួសាររបស់ខ្ញុំ។ បើទោះបីជាពីពេលដំបូង មានបញ្ហាពិបាក គម្លាតផ្នែកភាសា និងឧបសគ្គផ្នែកវប្បធម៌ខ្លះៗក៏ពិតមែន ក៏ប៉ុន្តែខ្ញុំពិតជាចាប់ផ្តើមស្រឡាញ់គ្រួសារម្ចាស់ផ្ទះរបស់ខ្ញុំ។

ពួកគេបានខិតខំប្រឹងប្រែងធ្វើអ្វីៗដែលគ្រួសារភាគច្រើនតែងធ្វើដើម្បីសមាជិកគ្រួសារនីមួយៗ។ ពួកគេធ្វើគ្រប់យ៉ាងដើម្បីឲ្យខ្ញុំបរិភោគបានឆ្អែត និងមានអារម្មណ៍ល្អ។ ពួកគេយកចិត្តទុកដាក់នៅពេលខ្ញុំមកផ្ទះ ឬនៅពេលខ្ញុំចេញទៅក្រៅ។ សំខាន់បំផុត ពួកគាត់ផ្តល់នូវក្តីស្រឡាញ់ដោយឥតលក្ខខណ្ឌចំពោះរូបខ្ញុំមិនថាថ្ងៃណាជាថ្ងៃនោះទេ។ ពួកគេតែងធ្វើឲ្យខ្ញុំសើច នឹងមានអារម្មណ៍កក់ក្តៅ។ ខ្ញុំពិតជាមានក្តីបារម្ភជាខ្លាំងអំពីស្ថានភាពគ្រួសារម្ចាស់ផ្ទះរបស់ខ្ញុំនៅក្នុងប្រទេសកម្ពុជា ដោយសារខ្ញុំពិតជាមិនដឹងថានឹងមានអ្វីកើតឡើងនោះទេ។ ក៏ប៉ុន្តែ បទពិសោធន៍នេះ គឺលើសពីអ្វីដែលខ្ញុំបានរំពឹងទុកទៅទៀត។ ខ្ញុំអាចនិយាយយ៉ាងមានទំនុកចិត្តថា មនុស្សដ៏គួរឲ្យស្រឡាញ់ទាំងនេះ នឹងក្លាយជាសមាជិកគ្រួសាររបស់ខ្ញុំពេញមួយជីវិត។ វាដល់ពេលដែលខ្ញុំត្រូវចាប់ផ្តើមត្រឡប់ទៅផ្ទះវិញ និងត្រូវនិយាយពាក្យលាគ្នាជាមួយពួកគេ ប៉ុន្តែខ្ញុំដឹងច្បាស់ថា យើងនឹងនៅភ្ជាប់ទំនាក់ទំនងជាមួយគ្នា ហើយខ្ញុំនឹងត្រឡប់ទៅលេងពួកគេវិញ។ ខ្ញុំចង់និយាយថា ការដែលទទួលបានការឱបពីក្មួយទាំងពីររបស់ខ្ញុំ គឺជាផ្នែកដ៏សំខាន់នៃជីវិតមួយនេះ ដែលខ្ញុំនឹកពួកគេនៅពេលដែលត្រឡប់ទៅដល់ផ្ទះវិញ។

បន្ថែមលើនេះ ខ្ញុំនឹងនឹកបងប្រុសម្ចាស់ផ្ទះ ដែលតែងនិយាយកំប្លែងជាមួយខ្ញុំ ហើយម្ចាស់ផ្ទះស្រីតែងណែនាំកូនៗរបស់គាត់ឲ្យទៅមុជទឹកនៅពេលយប់។ ខ្ញុំចង់ថ្លែងអំណរគុណដល់ក្រុមគ្រួសារម្ចាស់ផ្ទះសម្រាប់ការបង្រៀនខ្ញុំយ៉ាងច្រើន ដោយធ្វើឲ្យខ្ញុំក្លាយជាសមាជិកម្នាក់នៅក្នុងគ្រួសារ និងអរគុណដែលបានផ្តល់ឲ្យខ្ញុំនូវសេរីភាពតាមដែលខ្ញុំចង់បាន។ បទពិសោធន៍របស់ខ្ញុំ នឹងមិនអាចមានការប្រែប្រួលល្អប្រសើរបានឡើយ ប្រសិនបើគ្មានពួកគាត់នោះទេ។

## ខ្ញុំអរគុណគ្រួសារខ្មែររបស់ខ្ញុំខ្លាំងណាស់

ដោយ៖ អ្នកស្ម័គ្រចិត្ត មេហ្គាន វីជីស្ទ័រ



មេហ្គាន និងគ្រួសារខ្មែររបស់គាត់ ចូលរួមពិធីមង្គលការ

នៅពេលដែលខ្ញុំទទួលបានសំបុត្រពីកន្លែងស្នាក់នៅរបស់ខ្ញុំជាលើកដំបូង ខ្ញុំមានការភ័យខ្លាចតិចតួចដែរ។ ខ្ញុំមានភាពស្និទ្ធស្នាលជាមួយគ្រួសារម្ចាស់ផ្ទះដែលបានបណ្តុះបណ្តាលខ្ញុំ ហើយខ្ញុំបារម្ភថា ខ្ញុំនឹងមិនអាចកសាងទំនាក់ទំនងដូចគ្នាជាមួយគ្រួសារដែលខ្ញុំត្រូវស្នាក់នៅជាមួយអចិន្ត្រៃយ៍នោះបានឡើយ។ ខ្ញុំពិតជាមានការភ័យខ្លាចជាខ្លាំង ដោយសារក្នុងសំបុត្របានបញ្ជាក់ថា ខ្ញុំនឹងមានបងប្អូនប្រុសប្រាំពីរនាក់នៅក្នុងគ្រួសារម្ចាស់ផ្ទះ ចំណែករូបខ្ញុំវិញបានធំធាត់នៅក្នុងគ្រួសារដែលមានតែមនុស្សស្រីប៉ុណ្ណោះ។ ខ្ញុំមិនច្បាស់ថានឹងមានភាពកក់ក្តៅប៉ុណ្ណានោះទេនៅផ្ទះនោះ ជាពិសេសមិនថាខ្ញុំអាចពាក់អាវវាលលើ ឬស្លៀកខោខ្លីនៅផ្ទះបានដែរឬអត់នោះទេ។ (ខ្ញុំបានធ្វើតាមការណែនាំរបស់បងស្រីនិងបងស្រីថ្លៃរបស់ខ្ញុំ។)

បច្ចុប្បន្ននេះ ខ្ញុំមានអារម្មណ៍ដូចជានៅផ្ទះខ្លួនដែរនៅពេលនៅផ្ទះគ្រួសារម្ចាស់ផ្ទះ ប៉ុន្តែទំនាក់ទំនងល្អមិនមែនកើតឡើងក្នុងពេលមួយយប់នោះទេ និងក៏វាមិនអាចកើតមានដោយឯកឯងដែរ។ ដំបូង អ្វីៗចាប់ផ្តើមដោយភាពស្ងៀមស្ងាត់តានតឹងក្នុងចិត្តបំផុត ក្រោយមកក៏មានភាពធូរស្បើយក្នុងចិត្តនិងមាន ភាពកក់ក្តៅ - ការសាកសួរគ្នាទៅវិញទៅមកនិងការសាកសួរពីផែនការប្រចាំថ្ងៃ - និយាយដោយមានការដកឃ្លាប្រយោគ និងធ្វើតាមធម្មតាយ៉ាងងាយស្រួលបំផុត។ នៅប៉ុន្មានខែដំបូងនៅកន្លែង ខ្ញុំបានចំណាយពេលជាច្រើនជាមួយក្មួយប្រុសនិងក្មួយស្រីរបស់ខ្ញុំជាច្រើនអ្នក ហើយបន្តិចម្តងៗ ខ្ញុំបានប្រាស្រ័យទាក់ទងជាមួយមនុស្សធំ និងអាចឆ្លើយតបនឹងសំណួរដែលពួកគេសួរមកកាន់ខ្ញុំ។ ក្រៅពីខ្លួនខ្ញុំ សមាជិកគ្រួសារម្ចាស់ផ្ទះរបស់ខ្ញុំ បានក្លាយជាអ្នកគាំទ្រដ៏សំខាន់សម្រាប់រូបខ្ញុំនៅក្នុងសហគមន៍ដែលខ្ញុំស្នាក់នៅពួកគេតែងធ្វើគ្រប់យ៉ាងដើម្បីឲ្យខ្ញុំដឹងពីអ្វីដែលខ្ញុំត្រូវការពាក់ព័ន្ធនឹងព្រឹត្តិការណ៍នៅក្នុងសហគមន៍ ថ្ងៃឈប់សម្រាក និង "រឿងដែលគេចូលចិត្តនិយាយដើម"។ មនុស្សគ្រប់គ្នាស្គាល់ថាខ្ញុំជាកូនស្រីរបស់ សុខន ហើយខ្ញុំទទួលបានការស្វាគមន៍ខ្លាំង។

កាលពីឆ្នាំមុន ខ្ញុំមិនដែលនឹកស្រម៉ៃថាខ្ញុំនឹងអាចមានទំនាក់ទំនងជិតស្និទ្ធបែបនេះជាមួយក្រុមគ្រួសារបងប្អូនខ្មែរនោះទេ។ ពួកគេបានមកសួរសុខទុក្ខខ្ញុំនៅពេលខ្ញុំឈឺធ្ងន់ តែងខ្លួនឲ្យខ្ញុំយ៉ាងស្អាតពេលទៅញ៉ាំការ នឹងធ្វើរឿងជាច្រើនទៀត។ ពួកគេ គឺជាផ្នែកដ៏សំខាន់មួយនៃការបំពេញការងាររបស់ខ្ញុំ ហើយនៅពេលដែលការបញ្ចប់ការងារជាអ្នកស្ម័គ្រចិត្តកាន់តែខិតជិតចូលមកដល់ ខ្ញុំមិនដឹងខ្ញុំត្រូវពិបាកចិត្តយ៉ាងណានោះទេនៅពេលដែលខ្ញុំមិនអាចជួបពួកគេជារៀងរាល់ថ្ងៃតទៅទៀត។ ក្មួយស្រីរបស់ខ្ញុំបានសន្យាថានឹងទាក់ទងទៅខ្ញុំឲ្យបានញឹកញាប់នៅពេលខ្ញុំត្រឡប់ទៅសហរដ្ឋអាមេរិកវិញ។ ទំនាក់ទំនងដែលខ្ញុំបានបង្កើតជាមួយគ្រួសាររបស់ខ្ញុំនៅទីនេះ នឹងនៅជាប់ជាមួយខ្ញុំពេញមួយជីវិត ហើយនឹងបន្តជះឥទ្ធិពលលើទស្សនៈរបស់ខ្ញុំចំពោះពិភពលោកនិងមនុស្សយើងនេះ។

# បទពិសោធន៍នៃការធ្វើការជាមួយដៃគូការងារ

## អ្នកស្ម័គ្រចិត្ត ជាឡាស និង លោក សន ថេង

*ដោយ៖ អ្នកស្ម័គ្រចិត្ត ជាឡាស ស្មីត*



ជាឡាស និងលោក ថេង

នៅក្នុងការធ្វើដំណើររបស់ភ្នាក់ងារភីសខ័រ នៅក្នុងប្រទេសកម្ពុជា ខ្ញុំពិតជាមានកិត្តិយសជាខ្លាំងដែលបានបង្កើតមិត្តភាព និងកិច្ចសហការគ្នាជាមួយបុគ្គលនានានៅក្នុងសហគមន៍។ បងប្អូនប្រជាជនខ្មែរម្នាក់ ផ្តល់អត្ថន័យយ៉ាងធំធេងជាពិសេសចំពោះបទពិសោធន៍នេះ ហើយទំនាក់ទំនងនេះនឹងនៅបន្តជះឥទ្ធិពលមកលើជីវិតរបស់ខ្ញុំក្នុងរយៈពេលជាច្រើនឆ្នាំទៅមុខទៀត។ ស៊ិន ថេង គឺជាមនុស្សដ៏ល្អម្នាក់ ដែលបានដើរតួនាទីយ៉ាងច្រើននៅក្នុងព្រឹត្តិការណ៍សហគមន៍ទាំងគាត់នៅមានអាយុវ័យក្មេងបែបនេះ រាប់ចាប់តាំងពីការធ្វើការជាកសិករនៅពេលទំនេរ រហូតដល់ការបួសរៀនជាព្រះសង្ឃផងដែរ។ សម្រាប់រូបខ្ញុំផ្ទាល់ ថេង បានបង្រៀនភាសាខ្មែរដល់ខ្ញុំ និងបានជួយខ្ញុំនៅក្នុងការសិក្សាគម្ពីព្រះពុទ្ធសាសនា នៅពេលខ្ញុំបួសរៀន និងក្លាយជាមិត្តភក្តិដើរជាមួយគ្នា និងបន្តធ្វើជាមិត្តល្អរបស់ខ្ញុំនៅក្នុងសហគមន៍។

បច្ចុប្បន្ននេះ ថេង បានបន្តតួនាទីរបស់គាត់នៅក្នុងសហគមន៍តាមរយៈការធ្វើស្រែសរីរាង្គ។ តាមរយៈការចូលរួមក្នុងការបណ្តុះបណ្តាលរបស់ភ្នាក់ងារភីសខ័រ ស្តីពីសន្តិសុខស្បៀងនៅក្នុងខេត្តកំពត ក្តីស្រឡាញ់ពេញចិត្តក៏បានកើតមានឡើងនៅក្នុងខ្លួនរបស់ថេង ដើម្បីដាំដុះដំណាំសរីរាង្គ ដើម្បីលើកកម្ពស់សុខភាពរស់នៅរបស់សហគមន៍។ នៅដំណាក់កាលដំបូង នឹងដោយមានការដឹកនាំរបស់ថេង យើងបានបង្កើតនូវគំនិតធ្វើសួនបន្លែនៅតាមវត្តក្នុងមូលដ្ឋាន ដើម្បីលើកកម្ពស់ដល់អាហារូបត្ថម្ភសម្រាប់អ្នកដែលស្នាក់នៅក្នុងវត្ត។ ដោយមានការចូលរួមពីព្រះសង្ឃ នឹងដូនជីនៅតាមវត្ត គំនិតនេះបានបន្តរីកដុះដាលឈានដល់ការបង្កើតឲ្យមានជាសួនបន្លែមួយ។ ក៏ប៉ុន្តែ ថេង បានជ្រើសរើសបង្កើតផែនការធំជាងនេះ ដោយរួមផ្សំនូវការផ្តល់អំណាច ក្តីស្រឡាញ់ និងការអប់រំ។ គម្រោងបច្ចុប្បន្នរបស់ថេង រួមមានការប្រើប្រាស់ដីមានជីជាតិខ្ពស់នៅតាមសាលារៀនក្នុងមូលដ្ឋានដើម្បីបង្កើតសួនបន្លែជាច្រើនបន្ថែមទៀត។ តាមរយៈការជ្រើសរើសទីតាំងយ៉ាងប្រុងប្រយ័ត្ន សួនបន្លែនេះ នឹងត្រូវបានសហការដៃគូជាមួយវគ្គសិក្សាថ្នាក់កសិកម្មនៅវិទ្យាល័យដើម្បីធានានូវនិរន្តរភាពនៃគំនិតផ្តួចផ្តើមនេះ។ បន្ថែមលើភាពជាដៃគូនេះ ថេងបានបង្កើតនូវផែនការមួយដើម្បីផ្សារភ្ជាប់ផលិតផលសរីរាង្គស្រស់ៗដែលដាំដុះនៅតាមវិទ្យាល័យនេះ ជាមួយនឹងមនុស្សចាស់នៅក្នុងភូមិ ដែលពួកគាត់មានជំងឺសម្ពាធឈាមខ្ពស់ (លើសឈាម)។ ជាមួយនឹងបន្លែដែលកាត់បន្ថយនិងគ្មានជាតិគីមីនេះ ចក្ខុវិស័យនោះគឺដើម្បីធ្វើឲ្យអត្រាកើតជំងឺនិងស្លាប់ដោយសារជំងឺលើសឈាមនេះមានការធ្លាក់ចុះ តាមរយៈការផ្លាស់ប្តូររបៀបផែននៃការរស់នៅ។ ថេងបានបង្ហាញឲ្យឃើញពីការផ្តល់អំណាចដែលអាចកើតចេញពីការអប់រំ និងកិច្ចសហការគ្នា ហើយគាត់នឹងបន្តលើកកម្ពស់សុខភាពសហគមន៍របស់គាត់នាពេលអនាគតខាងមុខទៀត។

## អ្នកស្ម័គ្រចិត្ត ផាទ្រីសា និង ប្អូនស្រី សុថា

*ដោយ៖ អ្នកស្ម័គ្រចិត្ត ផាទ្រីសា*



ផាទ្រីសា និង ប្អូនស្រី សុថា

ក្រោយពេលមកដល់ទីតាំង ខ្ញុំចាំថាមានអារម្មណ៍ភ័យព្រួយចិត្តអំពីលទ្ធភាពនៅក្នុងការបង្កើតទំនាក់ទំនងជាមួយអ្នកដែលនឹងក្លាយជាដៃគូរការងាររបស់ខ្ញុំនាពេលខាងមុខ។ តាមអត្ថន័យរបស់ភ្នាក់ងារភីសខ័រ ដៃគូការងារ ត្រូវបានកំណត់និយមន័យថា៖ "បុគ្គលណាម្នាក់នៅក្នុងសហគមន៍ដែលអ្នកស្ម័គ្រចិត្តស្នាក់នៅជាមួយ ដែលបុគ្គលម្នាក់នោះត្រូវធ្វើការងារជាមួយអ្នកស្ម័គ្រចិត្ត។" ខ្ញុំមិនអាចបំភ្លេចថ្ងៃដំបូងរបស់ខ្ញុំនៅកន្លែងការងារបានឡើយ។ ខ្ញុំបានមកដល់តាំងពីព្រឹកព្រលឹម ក្នុងសម្លៀកបំពាក់ឯកសណ្ឋានការងារ និងត្រៀមខ្លួនរួចជាស្រេចដើម្បីសិក្សារៀនសូត្រ។ ខ្ញុំទទួលបានការស្វាគមន៍ពីស្ត្រីវ័យក្មេងម្នាក់ដោយការញញឹមយ៉ាងកក់ក្តៅ។ គាត់មានបទពិសោធន៍ និងជាពេទ្យឆ្មបដែលធ្វើដំណើរថ្មើរជើងជារៀងរាល់ថ្ងៃទៅកាន់មណ្ឌលសុខភាពនៅក្នុងភូមិជនបទមួយកន្លែងស្ថិតនៅតាមជើងភ្នំ ព័ទ្ធជុំវិញដោយវាលស្រែដ៏ស្រស់បំព្រង។ អ្នកគ្រូពេទ្យបានចាប់ដៃខ្ញុំ ហើយគាត់បាននិយាយមកកាន់ខ្ញុំថា "សួស្តី បងស្រី" ជាភាសាអង់គ្លេសមួយមាត់ពីរមាត់យ៉ាងល្អ និងជាមួយនឹងទឹកចិត្ត និងភាពជឿជាក់ហើយក៏មានឈ្មោះហៅក្រៅថា "បងស្រី" ជារាងរហូតមកបុគ្គលិកដែលខ្ញុំធ្វើការជាមួយ អ្នកក្បែរខាងក្នុងភូមិ អ្នកលក់ និងក្រុមគ្រួសាររបស់ខ្ញុំ ពួកគេហៅខ្ញុំថា "ប្អូនស្រី"។

ខ្ញុំកម្របៅដៃគូការងាររបស់ខ្ញុំថាជាដៃគូការងារពិតប្រាកដណាស់។ គាត់មានឈ្មោះ ជា សុថា ហើយខ្ញុំហៅគាត់ថា "ប្អូនស្រីសុថា"។ សុថា មានវ័យ ២០ឆ្នាំ រស់នៅជាមួយឪពុកម្តាយរបស់គាត់នៅក្នុងភូមិមួយដែលមានចម្ងាយប្រហែល១២គម ពីផ្ទះរបស់ខ្ញុំ។ គាត់សិក្សាភាសាអង់គ្លេសនៅថ្ងៃចុងសប្តាហ៍ នឹងឧស្សាហ៍ព្យាយាមធ្វើការ។ គាត់ស្រឡាញ់ចូលចិត្តសួនដំណាំ និងមានការលះបង់ខ្ពស់ចំពោះការងារ វប្បធម៌ ប្រពៃណី និងគ្រួសាររបស់គាត់។ សុថា នឹងខ្ញុំបានចូលរួមក្នុងការបណ្តុះបណ្តាលរបស់ភ្នាក់ងារភីសខ័រច្រើនដងជាមួយគ្នា យើងបានចែកអាហារគ្នាញ៉ាំជាច្រើនលើកច្រើនសារ យើងសើចសប្បាយទាំងអស់គ្នា ហើយបានចូលរួមទាំងអស់គ្នាធ្វើជាអ្នកកំដរកូនក្រមុំនៅក្នុងពិធីអាពាហ៍ពិពាហ៍មួយ។ សុថា មើលខុសត្រូវខ្ញុំនៅពេលមានខ្ញុំមានបញ្ហាលំបាក និងមិនដែលបោះបង់ខ្ញុំចោលឡើយ។ គាត់ជាអ្នកណែនាំ និងជាមគ្គុទេសក៍ផ្នែកសង្គមវប្បធម៌របស់ខ្ញុំ។ ខ្ញុំជួយគាត់នៅក្នុងការរៀនភាសាអង់គ្លេស។ ខ្ញុំបានចូលរួមនៅក្នុងគ្រួសាររបស់គាត់ដើម្បីប្រារព្ធពិធីបុណ្យតាមបែបខ្មែរ ហើយគាត់គឺជាមិត្តភក្តិនៃគ្រួសារខ្មែររបស់ខ្ញុំ និងទទួលបានការគោរពខ្លាំងពីក្រុមគ្រួសាររបស់ខ្ញុំ។

ទំនាក់ទំនងរបស់ខ្ញុំជាមួយសុថា មិនមានលក្ខណៈដោយផ្ទាល់នោះទេ។ ចំណុចល្អបំផុតរបស់សុថា គឺគាត់បានសិក្សាស្វែងយល់ពីរបៀបនៅក្នុងការធ្វើការងារជាមួយខ្ញុំ។ គាត់ដឹងពីរបៀបក្នុងការជួយជំរុញទឹកចិត្តខ្ញុំ និងគាំទ្រដល់រូបខ្ញុំ។ក្នុងនាមជាក្រុមការងារយើងផ្តល់ការអប់រំដល់អ្នកជំងឺដែលមានផ្ទៃពោះទាំងអស់គ្នា។ ខ្ញុំជួយគាត់តាមរយៈការប្រើប្រាស់សម្ភារៈឧបទេសដែលខ្ញុំបានបង្កើតឡើងដើម្បីពន្យល់ដល់អ្នកជំងឺអំពីអាហារូបត្ថម្ភ សញ្ញាគ្រោះថ្នាក់ និងរបៀបគ្រប់គ្រងផ្ទៃពោះឲ្យមានសុខភាពល្អ។ សុថា បានលើកទឹកចិត្តខ្ញុំឲ្យមានទំនុកចិត្តជាមួយនឹងភាសារបស់ខ្ញុំ និងផ្តល់ឧទាហរណ៍អំពីរបៀបនៃការរស់ស្វងដ៏មានប្រសិទ្ធភាពសម្រាប់ការយល់ដឹងពីអ្នកជំងឺរបស់យើង។ នៅក្នុងន័យរបស់ភ្នាក់ងារភីសខ័រ និងក្នុងន័យផ្ទាល់ខ្លួនរបស់ខ្ញុំ ខ្ញុំអាចកំណត់និយមន័យនៃពាក្យថាដៃគូការងារផ្សេងពីគ្នា។ ពិតណាស់ ដៃគូការងារគឺជាបុគ្គលដែលធ្វើការងារជាមួយនឹងអ្នកស្ម័គចិត្ត។ ដៃគូការងាររបស់ខ្ញុំ គឺមានន័យលើសពីនិយមន័យនេះទៅទៀត។ គាត់គឺជាបុគ្គលទីមួយដែលខ្ញុំបានជួបនៅថ្ងៃដំបូងនៅកន្លែងការងារ និងជាអ្នកនៅក្បែរខ្លួនខ្ញុំជានិច្ច។





































# កម្ពុជាបានបង្រៀនអ្ន

ភាពស្រណុក ភាពមោះមុត សេចក្តី

ថាមពល អនុស្សាវរីយ៍ ក

គ្រួសារ

Peace

លើកកម្ពស់ សន្តិភាពពិភព







































# ...កស្ម័គ្រចិត្តពីសខ័រអំពី

...ស្រលាញ់ ស្នាមញញឹម សហគមន៍

...ការដឹងគុណ ការអត់ធ្មត់

...ផ្ទះ ...

... Corps

## ...លោក និង កសាងមិត្តភាព






**ព័ត៌មានទំនាក់ទំនង៖**

ភ្នាក់ងារ ភីសខ័រប្រចាំនៅកម្ពុជា
ប្រអប់សំបុត្រលេខ ២៤៥៣ ភ្នំពេញ ៣ ព្រះរាជាណាចក្រកម្ពុជា
ផ្ទះលេខ ៧អា ផ្លូវលេខ ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ

ទូរស័ព្ទលេខ៖ +៨៥៥ ២៣ ២២២ ៩០១
ទូរសារលេខ៖ +៨៥៥ ២៣ ២២២ ៩០៣

អ៊ីមែល៖ info@kh.peacecorps.gov
គេហទំព័រ៖ http://peacecorps.gov/cambodia

**ស្វែងរកយើងតាម៖**

cambodia.peacecorps
peacecorpscambodia
PCCambodia



Peace Corps

ភីសខ័រ គឺជាស្ថាប័នដែលមិនប្រកាន់និន្នាការនយោបាយ និង សាសនា របស់រដ្ឋាភិបាល សហរដ្ឋអាមេរិក ដែលធ្វើការដើម្បីលើកកម្ពស់សន្តិភាព និង មិត្តភាពរវាងប្រជាជននៃប្រទេស និងវប្បធម៌ផ្សេងៗគ្នា ។ អស់រយៈពេលជាងប្រាំទសវត្សកន្លងទៅនេះ ភ្នាក់ងារ ភីសខ័របានផ្តល់ជំនួយបច្ចេកទេសដល់ប្រទេសចំនួន១៤១ តាមរយៈការអនុវត្តគំរោងក្នុងវិស័យអប់រំ ការអភិវឌ្ឍអាជីវកម្ម ការការពារបរិស្ថាន កសិកម្ម និងសុខភាព ។

ខែកុម្ភៈ ឆ្នាំ២០១៩